## ផ្នែក ឃ

# ការធ្វើផែនការ
# ចំណាកស្រុក
# ប្រកបដោយសុវត្ថិភាព



# ១៩ មេរៀនទី១៩ ៖ ជំនាញក្នុងការធ្វើសេចក្ដីសម្រេចចិត្ត

**វត្ថុបំណង**

ចូលរួមនឹងពិចារណាអំពីរបៀបដែលគេធ្វើសេចក្ដីសម្រេចចិត្ត នឹងដឹងថា តើព័ត៌មានអ្វីខ្លះដែលត្រូវប្រមូល និងវាយតម្លៃដើម្បីធ្វើសេចក្ដីសម្រេច ចិត្តដឹងព័ត៌មានច្បាស់នៅថ្ងៃក្រោយ។

**ពេលវេលា**

៧៥ នាទី

**សម្ភារៈ**

- ក្រដាសផ្ទាំងធំ

  ថតចម្លងមួយច្បាប់នូវ "IS ១៩ក ៖ គំរូនៃការសម្រេចចិត្ត" នៅលើក្រដាសផ្ទាំងធំ ដែលដាក់បង្ហាញនៅកន្លែងណាដែលសិស្សអាចមើលឃើញច្បាស់។
- ថតចម្លង ៤-៦ ច្បាប់ នូវ "IS ១៩ខ ៖ គំរូនៃការធ្វើសេចក្ដី សម្រេចចិត្តសម្រាប់ការ ធ្វើចំណាកស្រុក " និងន "IS ១៩គ ៖ ករណីសិក្សាអំពីការធ្វើសេចក្ដីសម្រេច ចិត្ត" ( សិស្សនឹង បែងចែកជាក្រុម មានគ្នាពី ៤-៦ នាក់ ហើយមួយក្រុមនឹងត្រូវការ មួយច្បាប់នៃ IS)
- កូនសៀវភៅអំពីការចង្អុលបង្ហាញជំនួតវែ

**សេចក្ដីផ្ដើម**

**ការស្វាគមន៍**

ស្វាគមន៍យុវជនដោយហៅឈ្មោះ។ ហុចតៗគ្នានូវបញ្ជីចុះហត្ថលេខាវត្តមាន។

**សកម្មភាពមុនចាប់ផ្ដើម**

ឲ្យអ្នកសម្របសម្រួលជាយុវជនដឹកនាំល្បែងថាមពលនៅក្នុងតារាង។

**ការរំឭកមេរៀន**

តើមាននរណាអាចចាំបានពីវិធីក្នុងការរក្សាសុវត្ថិភាពពីអ៊ិនធឺណិតដែរ ឬទេ?

## ការណែនាំអំពីគំរូនៃការធ្វើសេចក្ដីសម្រេចចិត្ត

ពន្យល់ថា ជីវិតគឺពោរពេញទៅដោយការសម្រេចចិត្ត។ មានការសម្រេចចិត្តតូចតាចមួយចំនួនដូចជាត្រូវនិយាយជាមួយនរណាញ៉ាំអីស្លៀកពាក់អីហើយក៏មានការសម្រេចចិត្តធំៗដូចជា ថា តើត្រូវនៅបន្តសិក្សា ឬយ៉ាងណាត្រូវធ្វើការនៅទីណា និងត្រូវរៀបការជាមួយនរណា។ ឲ្យអ្នកចូលរួមផ្ដល់ឧទាហរណ៍អំពីការសម្រេចចិត្តធំៗនៅក្នុងជីវិត។ សរសេរឧទាហរណ៍របស់គេនៅលើក្រដាសផ្ទាំងធំពេលគេកំពុងនិយាយ។

ពេលនេះឲ្យអ្នកចូលរួមគិតអំពីពេលវេលានៅក្នុងជីវិតរបស់គេផ្ទាល់នៅពេលដែលគេបានធ្វើសេចក្ដីសម្រេចចិត្តធំៗ ។ សួរទៅគេថា ៖

- តើអ្នកចាំទេថា អ្នកធ្វើសេចក្ដីសម្រេចចិត្តដោយរបៀបណា?
- តើអ្នកបាននិយាយជាមួយអ្នកដទៃអំពីការសម្រេចចិត្តដែរ ឬទេ?
- តើអ្នកបាននិយាយជាមួយនឹងមិត្តភក្តិ ក្រុមគ្រួសារ គ្រូរបស់អ្នក ឬអ្នកដឹកនាំសាសនាដែរទេ?
- តើអ្នកធ្វើសេចក្ដីសម្រេចចិត្តដោយខ្លួនឯង ឬឲ្យអ្នកផ្សេងសម្រេចជំនួសអ្នក?

ពន្យល់ថា មនុស្សតែងធ្វើសេចក្តីសម្រេចចិត្តជាច្រើនដែលជាផ្នែកមួយនៃជីវិត។ ជាធម្មតា មនុស្សមិនបានគិតច្រើនអំពីដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្តទេ គឺគេតែម្តងៗ ហើយជម្រើសដែលមនុស្សជ្រើសយកគឺអាចកំណត់ឆាកជីវិតរបស់គេ។ ការសម្រេចចិត្តគឺមានលក្ខណៈផ្ទាល់ខ្លួនបំផុត។ វារងឥទ្ធិពលពីក្រុមគ្រួសារឱកាសនិង បុគ្គលិកលក្ខណៈផ្ទាល់ខ្លួន។ ដូច្នេះ មិនអាចបរិយាយ បានអំពីប្រព័ន្ធល្អបំផុតមួយសម្រាប់ការធ្វើសេចក្តីសម្រេចចិត្តដ៏ល្អមួយបានទេ។ មេរៀននេះពិភាក្សាអំពីជំហានមួយចំនួនដែលត្រូវអនុវត្តនៅពេលដែលជួបប្រទះនឹងការធ្វើសេចក្តីសម្រេចចិត្តធំៗដើម្បីក្នុងការដំណើរការនេះ។

ពន្យល់ថាមានគំរូជាច្រើនដែលមនុស្សប្រើប្រាស់នៅពេលធ្វើសេចក្តីសម្រេចចិត្ត។ អ្វីដែលជាគំរូទាំងនេះមានលក្ខណៈជារួមគឺ វាជួយដល់មនុស្សឲ្យគិតយ៉ាងប្រុងប្រយ័ត្នអំពីការសម្រេចចិត្ត និងក្នុងការគិតទុកមុនថា តើលទ្ធផលនៃការធ្វើសេចក្តីសម្រេចចិត្តនឹងអាចទៅជាយ៉ាងណា។ ប្រាប់អ្នកចូលរួមថា មានគំរូមួយដែលអាចជួយដល់ពួកគេក្នុងការគិតអំពីការសម្រេចចិត្ត។ ចង្អុលទៅរូបភាពអំពីគំរូនៃការធ្វើសេចក្តីសម្រេចចិត្តនៅលើក្រដាសផ្ទាំងធំ។ ចែកកូនសៀវភៅវៃឆ្លាតវៃដល់អ្នកចូលរួម ហើយឲ្យគេបើកទៅទំព័រនិយាយអំពី “គំរូអំពីការសម្រេចចិត្ត”។

ឲ្យអ្នកចូលរួមមើលគំរូក្នុងពេលដែលអ្នកកំពុងបរិយាយអំពីជំហាននីមយៗ ។

- ជំហានទី ១៖ សំណួរអំពីការសម្រេចចិត្ត
  - បំផុសសំណួរលើការសម្រេចចិត្តដែលអ្នកកំពុងព្យាយាមធ្វើ។
- ជំហានទី ២៖ សិក្សាបន្ថែម
  - សិក្សាបន្ថែមអំពីជម្រើសរបស់អ្នក។ សួរទៅមនុស្សនៅក្នុងសហគមន៍ដែលដឹងអំពីរឿងនេះ។ ពិភាក្សាជាមួយមនុស្សដែលអ្នកជឿជាក់លើមតិយោបល់របស់គេ។ សួរមិត្តភក្តិរបស់អ្នក។ និងសួរលោកគ្រូ/អ្នកគ្រូរបស់អ្នក។
- ជំហានទី ៣ ៖ រៀបរាប់ពីជម្រើសផ្សេងៗ
  - ត្រូវរៀបរាប់ឲ្យបានយ៉ាងហោចជម្រើស បី ផ្សេងទៀត។ ជម្រើសផ្សេងគឺ ជាចម្លើយផ្សេងទៅនឹងសំណួរដែលអ្នកបានសួរពីខាងដើម។
  - នៅពេលដែលអ្នកពិចារណាអំពីជម្រើសផ្សេងទៀត ចូរចងចាំថា ការពន្យារពេលធ្វើសេចក្តីសម្រេចចិត្តគឺជាញឹកញាប់វាជាជម្រើសមួយដែរ។
  - នៅពេលដែលអ្នកពិចារណាអំពីជម្រើសផ្សេងទៀត ចូរគិតអំពីជម្រើសដែល កាត់បន្ថយហានិភ័យ។
- ជំហានទី ៤៖ ការវាយតម្លៃពីហានិភ័យ និងអត្ថប្រយោជន៍
  - គិតពីលទ្ធផលដែលអាចកើតមានលើជម្រើសនីមួយៗ។ សម្រាប់ជម្រើសនីមួយៗ ត្រូវគិតពីហានិភ័យ និងអត្ថប្រយោជន៍។ សរសេរចំណុចទាំងនេះនៅក្នុងរង្វង់។
- ជំហានទី៥ ៖ ធ្វើសេចក្តីសម្រេចចិត្តរបស់អ្នក

ផ្តល់ឧទាហរណ៍អំពីរបៀបដែលគំរូនេះអាចដំណើរការ ដោយប្រើគំរូធំនៅលើក្រដាសផ្ទាំងធំ។

**ជំហានទី ១ ៖ សំណួរអំពីការសម្រេចចិត្ត**

ពន្យល់ថា ល កំពុងគិតថា គេគួរតែរកងារធ្វើនៅទីក្រុង ឬយ៉ាងណា។ សរសេរការគិតនេះចេញ ជាសំណួរមួយ។

"តើខ្ញុំគួរតែទៅរកការងារធ្វើនៅទីក្រុងឬទេ?"

**ជំហានទី ២៖ សិក្សាបន្ថែម**

សួរអ្នកចូលរួមថា"តើនរណាអាចដឹងច្រើនអំពីការងារនៅទីក្រុង? អ្នកគួរសួរអ្នកដែលធ្លាប់បានធ្វើចំណាកស្រុក។ អ្នកអាចសួរលោកគ្រូ/អ្នកគ្រូរបស់អ្នក។ អ្នកអាចសិក្សាអំពីទីក្រុងនិងថា តើត្រូវចំណាយប៉ុន្មានដើម្បីរស់នៅទីនោះបាន ហើយតើការងារប្រភេទណាដែលគេធ្វើ។" អ្នកសម្របសម្រួល គួរបំពេញក្នុងប្រអប់នៅក្នុងរូបភាពនូវចម្លើយដែលអាចទៅរួច ឧទាហរណ៍ថា "ការងារនៅទីក្រុងទទួលបានកម្រៃ ១០០ ដុល្លារអាមេរិក ក្នុងមួយខែ ដោយត្រូវចំណាយ ៣០ ដុល្លារសម្រាប់បន្ទប់រួមគ្នា និងប្រហែលជា ៤០ ដុល្លារសម្រាប់អាហារ។ ល ស្គាល់មិត្តម្នាក់ដែលដឹងពីកន្លែងដែលអាចនៅរួមគ្នាបាន។ ខ្ញុំអាចទូរស័ព្ទទៅនាងសួរថា តើនាងរកការងារបានធ្វើដោយរបៀបណា។"

**ជំហានទី ៣៖ រៀបរាប់ពីជម្រើសផ្សេងទៀត**

រៀបរាប់ពីជម្រើសផ្សេងទៀតដែលអាចកាត់បន្ថយហានិភ័យ។ ឧទាហរណ៍ ៖

ជម្រើសទី ១៖ ធ្វើដំណើរទៅទីក្រុងពេលនេះ ដោយមិនបាច់សន្សំប្រាក់ និងរកការងារធ្វើតែម្តង។

ជម្រើសទី២៖រង់ចាំរហូតទាល់តែខ្ញុំសន្សំប្រាក់បានខ្លះនិងរហូតទាល់តែខ្ញុំបានរៀបចំការងារមួយសិន។

ជម្រើសទី ៣៖ រង់ចាំរហូតទាល់តែខ្ញុំបានបញ្ចប់វិទ្យាល័យសិន ហើយបន្ទាប់មកទៅទីក្រុងតែម្តង។

**ជំហានទី ៤៖ វាយតម្លៃលើហានិភ័យ និងអត្ថប្រយោជន៍នានា**

បន្ទាប់មកវាយតម្លៃជាមួយក្រុមលើហានិភ័យនិងអត្ថប្រយោជន៍ (ទាំងអត្ថប្រយោជន៍រយៈពេលខ្លី និងរយៈពេលវែង)។

អានឧទាហរណ៍ខាងក្រោមឲ្យឮៗពេលអ្នកបំពេញក្នុងគំរូ។ ៖

**ជម្រើសទី ១៖ ធ្វើដំណើរទៅទីក្រុងពេលនេះ ដោយមិនបាច់សន្សំប្រាក់ និងរកការងារធ្វើតែម្តង**

ហានិភ័យ ៖ ខ្ញុំមិនស្គាល់នរណាម្នាក់នៅទីក្រុងទេ។ ខ្ញុំមិនដឹងជាស្នាក់នៅកន្លែងណាទេ។ ប្រសិនបើខ្ញុំរកការងារមិនបានធ្វើ ខ្ញុំមិនដឹងជារកប្រាក់ដោយរបៀបណាទេ។ ខ្ញុំនឹងក្លាយជាជនងាយរងគ្រោះដោយអំពើជួញដូរមនុស្ស។ ហានិភ័យរយៈពេលខ្លីមានកម្រិតខ្ពស់ណាស់។ ខ្ញុំក៏ត្រូវបញ្ឈប់ការសិក្សារបស់ខ្ញុំផងដែរ ដែលមានន័យថា ហានិភ័យរយៈពេលវែងក៏មានកម្រិតខ្ពស់ដែរ។

អត្ថប្រយោជន៍ ៖ ប្រសិនបើអាចទៅរួច ខ្ញុំនឹងរកប្រាក់បានភ្លាមៗ។ ក្នុងរយៈពេលខ្លីប៉ុណ្ណោះ។

**ជម្រើសទី ២៖ រង់ចាំរហូតទាល់តែខ្ញុំសន្សំប្រាក់បានខ្លះ និងរហូតទាល់តែខ្ញុំបានរៀបចំការងារសិន។**

ហានិភ័យ ៖ ខ្ញុំនឹងមានប្រាក់ដើម្បីរស់ក្នុងរយៈពេលខ្លីប៉ុណ្ណោះ ប៉ុន្តែខ្ញុំនឹងមានហានិភ័យចំពោះអនាគតរបស់ខ្ញុំដោយមិនទទួលបានសញ្ញាបត្រកម្រិតមធ្យមសិក្សាទេ។

អត្ថប្រយោជន៍ ៖ ខ្ញុំអាចនឹងខកខានមិនបានរកប្រាក់ក្នុងរយៈពេលខ្លី ប៉ុន្តែខ្ញុំនឹងមានអត្ថប្រយោជន៍រយៈពេលវែង ពីព្រោះខ្ញុំអាចទទួលបានការងារមួយដែលមានកម្រៃល្អប្រសិនបើខ្ញុំមានផែនការច្បាស់។

**ជម្រើសទី ៣៖ រង់ចាំរហូតទាល់តែខ្ញុំបានបញ្ចប់វិទ្យាល័យសិន ហើយបន្ទាប់ទៅទីក្រុងតែម្ដង**

ហានិភ័យ ៖ វាអាចនឹងលំបាកសម្រាប់គ្រួសាររបស់ខ្ញុំក្នុងការទ្រទ្រង់គ្រួសារទាំងមូល ប្រសិនបើខ្ញុំរង់ចាំរហូតទាល់តែខ្ញុំរៀនចប់។

អត្ថប្រយោជន៍ ៖ វាមានសុវត្ថិភាពជាងក្នុងការផ្លាស់ទី ប្រសិនបើខ្ញុំមានផែនការទុកមុន។ ខ្ញុំនឹងទទួលបានការងារមួយដែលមានកម្រៃល្អប្រសិនបើខ្ញុំបញ្ចប់ការសិក្សាថ្នាក់វិទ្យាល័យ។

**ជំហានទី ៥ ៖ ការធ្វើសេចក្ដីសម្រេចចិត្ត**

នៅពេលអ្នកប្រមូលបានព័ត៌មានទាំងអស់ដោយប្រើគំរូនៃការសម្រេចចិត្តរួចចូរអានឡើងវិញ។ជាធម្មតាវាជាគំនិតល្អដែលត្រូវរង់ចាំពីរ បីថ្ងៃ ឬសប្ដាហ៍មុនពេលអ្នកធ្វើការសម្រេចចិត្តសំខាន់មួយដើម្បីពិនិត្យមើលថា គំនិត និងអារម្មណ៍របស់អ្នកមានការប្រែប្រួលដែរទេ។

## ករណីសិក្សា

បែងចែកអ្នកចូលរួមជាក្រុមដែលមានគ្នាពី ៤-៦ នាក់។ ផ្ដល់ឲ្យក្រុមនីមួយៗនូវករណីសិក្សាមួយក្នុងចំណោមករណីសិក្សាពីរពី “IS ១៩គ ៖ ករណីសិក្សាសម្រាប់ការធ្វើសេចក្ដីសម្រេចចិត្ត” និងរូបថតមួយនៃ “IS ១៩ក ៖ គំរូនៃការសម្រេចចិត្ត”។

ឲ្យក្រុមទាំងអស់បំពេញក្នុងគំរូដោយផ្អែកលើករណីសិក្សារបស់ខ្លួន។ លើកទឹកចិត្តគេឲ្យប្រើការគូររូប និងការសរសេរដើម្បីបំពេញប្រអប់។ ១០ នាទីក្រោយមកឲ្យក្រុមទាំងអស់ចែករំលែកលទ្ធផលរបស់គេ។

## នៅពេលដែលគំរូមិនគ្រប់គ្រាន់

បន្ទាប់មក អ្នកសម្របសម្រួលគួរពន្យល់ថា គំរូនេះធ្វើឲ្យងាយស្រួលក្នុងការធ្វើសេចក្ដីសម្រេចចិត្ត ប៉ុន្តែជាក់ស្តែង វាមិនមែនសុទ្ធតែជារឿងសាមញ្ញនោះទេ។

អានរឿងខាងក្រោមឲ្យឮ ៖

ម រស់នៅក្នុងភូមិក្រីក្រមួយនៅលើភ្នំ។ នាងមានអាយុ ១៥ ឆ្នាំ ហើយនាងមានប្អូនស្រីពីរនាក់។ ម្ដាយរបស់នាងបានស្លាប់ចោល ហើយឪពុករបស់នាងតែងតែផឹកស្រាស្រវឹងជោគ។ ពេលខ្លះគាត់អាចត្រឡប់មកផ្ទះពេលចុងសប្ដាហ៍ វាយកំទិចរបស់របរក្នុងផ្ទះវាយនាង និងប្អូនៗរបស់នាង។ ម បានឈប់រៀន និងធ្វើការនៅក្នុងឡឥដ្ឋមួយក្បែរនោះដើម្បីរកប្រាក់ឲ្យប្អូនៗរបស់នាង បានរៀន។ ថ្ងៃមួយឪពុករបស់ ម បានវាយដំ ម យ៉ាងធ្ងន់ធ្ងរពេលនោះថៅកែស្រីរបស់នាងដែលបានរៀបការជាមួយប្ដីប៉ូលីសម្នាក់ បានប្រាប់នាងឲ្យរាយការណ៍ពីឪពុករបស់នាងទៅប៉ូលីសទៅ។ ប៉ូលីសអាចនឹងចាប់ខ្លួនឪពុករបស់ ម។ វាអាចជាការលំបាកខ្លាំងណាស់សម្រាប់ ម ក្នុងការប្រើគំរូដើម្បីធ្វើការសម្រេចចិត្ត។

អ្នកអាចអនុវត្តតាម **ជំហានទី ១ ៖** “តើខ្ញុំគួរតែរាយការណ៍ពីឪពុករបស់ខ្ញុំទៅប៉ូលីសដែរ ឬទេ?” **ជំហានទី ២** អាចកាន់តែស្មុគស្មាញទៀត ពីព្រោះមានរឿងជាច្រើនដែលត្រូវពិចារណា។ អ្នកអាចនឹងត្រូវគិតផងដែរថា តើឪពុករបស់នាងត្រូវនៅក្នុងគុករយៈពេលប៉ុន្មាន ថាតើនាងត្រូវនៅក្នុង

ផ្ទះរបស់នាងដោយគ្មានឪពុករបស់នាង ឬយ៉ាងណា? ថាតើមានសាច់ញាតិរបស់នាងអាចមើលថែប្អូនៗរបស់នាង ឬយ៉ាងណា និងថាតើនាងអាចទ្រទ្រង់ប្អូនរបស់នាងដោយមិនមានចំណូលពីឪពុករបស់នាង ឬយ៉ាងណា គឺវាអាចមានគ្រោះថ្នាក់សម្រាប់នាងក្នុងការសួរសំណួរទាំងនេះ ក្នុងករណីដែលឪពុករបស់នាងដឹង និងដាក់ទោសនាងដោយសារតែសំណួរទាំងនេះ។

**ជំហានទី៣**

ពិចារណាអំពីជម្រើសពីរ៖

១. ម រាយការណ៍ពីឪពុករបស់នាងទៅប៉ូលីស ។

២. ម មិនរាយការណ៍ពីឪពុករបស់នាងទៅកាន់ប៉ូលីសទេ។

**ជំហានទី ៤**

ជម្រើសទាំងនេះ មានហានិភ័យស្មុគស្មាញបំផុត ដែលភាគច្រើនពិបាកនឹងព្យាករណ៍ណាស់។

**ជម្រើសទី ១ ៖ ម រាយការណ៍ពីឪពុករបស់នាងទៅប៉ូលីស**

ហានិភ័យ ៖ គាត់មិនត្រូវបានផ្ដន្ទាទោស ហើយត្រូវបានដោះលែងវិញ។ គាត់នឹងខឹងខ្លាំងណាស់ ហើយនឹងព្យាយាមសម្លាប់ ម មិនខាន។

បើគាត់ត្រូវបានផ្ដន្ទាទោស ម និងប្អូនៗរបស់នាងត្រូវបង្ខំឲ្យទៅរស់នៅជាមួយសាច់ញាតិផ្សេងទៀត។ ប្អូនៗរបស់នាងនឹងឈប់រៀន។ ម មានក្ដីបារម្ភថា ប្អូនស្រីរបស់នាងនឹងស្ថិតក្នុងហានិភ័យនៃការជួញដូរ ពីព្រោះ ម មិនជឿជាក់លើសាច់ញាតិរបស់នាងទេ។

ឲ្យក្រុមគិតពីហានិភ័យ និងអត្ថប្រយោជន៍បន្ថែមទៀត។

**ជម្រើសទី ២៖ ម មិនរាយការណ៍ពីឪពុករបស់នាងទៅកាន់ប៉ូលីសទេ**

ហានិភ័យ៖ ឪពុករបស់នាងនៅតែបន្តវាយដំនាង និងប្អូនៗរបស់នាងរហូតទាល់តែថ្ងៃណាមួយគាត់ចាកចេញឆ្ងាយហើយស្លាប់។ ប្អូនរបស់រត់ចេញពីផ្ទះដោយមិនប្រាប់ដំណឹងគេបន្ទាប់ពីការវាយដំហើយត្រូវបានគេជួញដូរ។ ឲ្យក្រុមគិតពីហានិភ័យ និងអត្ថប្រយោជន៍បន្ថែមទៀត។

**ជំហានទី ៥**

បន្ទាប់មកទៀត អ្នកសម្របសម្រួលពន្យល់ថា វាអាចមានការលំបាកខ្លាំងណាស់សម្រាប់ ម ក្នុងការសម្រេចចិត្ត។ ហេតុអ្វីបានជាបែបនេះ?

- មានទិដ្ឋភាពជាច្រើននៃការសម្រេចចិត្តដែលនាងមិនមានអំណាចលើវា។
- នាងស្ថិតក្នុងគ្រោះថ្នាក់ជាប្រចាំ ។
- ការស្ថិតក្នុងគ្រោះថ្នាក់អាចធ្វើឲ្យពិបាកក្នុងការគិតគូរបានច្បាស់លាស់។
- មិនមានចម្លើយងាយស្រួលទេ។

តមកទៀត អ្នកសម្របសម្រួលគួរពន្យល់ថា វាអាចជាការប្លែកបន្តិចដែលអ្នកចូលរួមត្រូវបានសុំឲ្យសាកល្បងអនុវត្តគំរូនៃការសម្រេចចិត្ត ហើយបន្ទាប់មកត្រូវបានបង្ហាញថា វាមិនមែនសុទ្ធតែអាចទៅរួចគ្រប់ពេលនោះទេ។ មូលហេតុនៃការធ្វើបែបនេះគឺដើម្បីបង្ហាញពីរបៀបដែលជីវិតអាចមានភាពស្មុគស្មាញបែបណា។ មេរៀនអំពីគំរូនៃការសម្រេចចិត្តគឺដើម្បីជួយដល់គេឲ្យបានដឹងច្បាស់អំពីការសម្រេចចិត្ត ប៉ុន្តែគេគួរបានដឹងផងដែរថា មិនមែនរាល់ការសម្រេចចិត្ត ឬបញ្ហាទាំងអស់សុទ្ធតែមានដំណោះស្រាយច្បាស់លាស់នោះទេ។

## ការពិភាក្សា

ឲ្យក្រុមឈប់ និងគិតអំពីគំរូនៃការធ្វើសេចក្តីសម្រេចចិត្តម្តងទៀត។
សួរថា៖

- តើគំរូនៃការធ្វើសេចក្តីសម្រេចចិត្តអាចដំណើរការបានល្អក្នុងករណីខ្លះដែរ ឬទេ?
- តើអ្នកអាចឲ្យជាឧទាហរណ៍មួយដែលអាចជួយឲ្យអ្នកធ្វើសេចក្តីសម្រេចចិត្តបានដែរ ឬទេ? ឲ្យឧទាហរណ៍មួយដែលមិនអាចជួយអ្នកក្នុងការធ្វើសេចក្តីសម្រេចចិត្ត?
- ចុះអំពីឧទាហរណ៍មួយអំពីការសម្រេចចិត្តដែលវាមិនអាចជួយអ្នកឲ្យធ្វើបានវិញ?
- តើអ្នកនឹងប្រើគំរូនេះនៅក្នុងជីវិតរបស់អ្នកដែរ ឬទេ? ហេតុអ្វីប្រើ? មិនប្រើ?

## កំណត់ហេតុ

ឲ្យក្រុមអ្នកចូលរួមសរសេរ ឬគូររូបនៅក្នុងកំណត់ហេតុរបស់គេរយៈពេល ១០ នាទីអំពីប្រធានបទ ដែលគេចង់ធ្វើ។

### សង្ខេបមេរៀន

- គំរូការធ្វើសេចក្តីសម្រេចចិត្តអាចជួយឲ្យយើងគិតបានកាន់តែច្បាស់ និងប្រុងប្រយ័ត្នអំពីការសម្រេចចិត្ត។
- ជំហានទាំងប្រាំនៃគំរូការសម្រេចចិត្តមាន ៖
  - ជំហានទី១ ៖ បរិយាយការសម្រេចចិត្តរបស់អ្នកជាសំណួរមួយ។
  - ជំហានទី២ ៖ សិក្សាបន្ថែម។
  - ជំហានទី ៣៖ រៀបរាប់ពីជម្រើសផ្សេងទៀត។
  - ជំហានទី ៤ ៖ វាយតម្លៃហានិភ័យ និងអត្ថប្រយោជន៍។
  - ជំហានទី ៥ ៖ ធ្វើការសម្រេចចិត្តរបស់អ្នក។
- គំរូនៃការសម្រេចចិត្តមិនដំណើរការសម្រាប់គ្រប់ការសម្រេចចិត្តទាំងអស់នោះទេ។
- វាពិបាកណាស់ ក្នុងការធ្វើសេចក្តីសម្រេចចិត្ត នៅពេលដែលអ្នកមិនមានសុវត្ថិភាព ឬមានការភ័យខ្លាច។

## ការបិទបញ្ចប់

ប្រាប់ឲ្យអ្នកចូលរួមសរសេរ ឬសួរសំណួរ ឬ ផ្តល់ជាព័ត៌មានត្រឡប់ និងប្រគល់ឲ្យទៅអ្នកសម្របសម្រួលដោយមិនបាច់បញ្ចេញឈ្មោះ។
អរគុណដល់អ្នកចូលរួមទាំងអស់គ្នាដែលបានចូលរួម។ បញ្ជាក់ឡើងវិញអំពីការប្រជុំគ្លិបពេលក្រោយ។ ប្រាប់ពួកគេថា ពួកគេទទួលបានផ្កាយមួយទៀតសម្រាប់ការចូលរួមក្នុងមេរៀននេះ។ (ប្រសិនបើមានអ្នកមិនចេះអក្សរនៅក្នុងក្រុម មិនត្រូវបញ្ចប់ជំហានបន្ទាប់ទេ។ ជំនួសមកវិញ ឲ្យពួកគេគិតថា តើគំរូនេះមានសារៈប្រយោជន៍នៅក្នុងជីវិតរបស់ពួកគេយ៉ាងដូចម្តេច)។
ឲ្យអ្នកចូលរួមស្វែងរកឱកាសដើម្បីប្រើគំរូការសម្រេចចិត្តនេះ រួមទាំងនៅក្នុងកូនសៀវភៅនារីកវល្លារបស់គេផងដែរ មុនពេលសិក្សាមេរៀនបន្ទាប់ទៀត។ ប្រសិនបើគេនៅសល់ម៉ោងគេអាចបំពេញគំរូនៃការសម្រេចចិត្ត និងយកត្រឡប់មកវិញនៅពេលជួបគ្នាក្នុងមេរៀនបន្ទាប់។

# ១៩ IS ១៩ក៖ គំរូនៃការសេចក្ដីសម្រេចចិត្ត






## ១៩ IS ១៩២ ÷ គំរូនៃការសម្រេចចិត្តសម្រាប់ការធ្វើចំណាកស្រុក

# ឧទាហរណ៍អំពីគំរូនៃការធ្វើសេចក្តីសម្រេចចិត្ត

| សំនួរ | សិក្សាបន្ថែម | ជំរើស | លទ្ធផល | កាត់បន្ថយហានិភ័យ | ការសំរេចចិត្ត |
|---|---|---|---|---|---|
| តើខ្ញុំគួរទៅទីក្រុងដើម្បីស្វែងរកការងារធ្វើដែរឬទេ? | • សាកសួរអ្នកមានបទពិសោធន៍<br>• ជជែកជាមួយឪពុកម្តាយ<br>• ជជែកជាមួយលោកគ្រូ អ្នកគ្រូ<br>• ជាមធ្យមទទួលប្រាក់ខែប៉ុន្មាន?<br>• តំលៃនៃការស្នាក់នៅ<br>• ថ្លៃឈប់សំរាក<br>• ប្រាក់កំរៃ<br>• ពេលវេលាធ្វើការ | **ជំរើសទី១**<br>ទៅឥឡូវដោយមិនចាំបាច់មានលុយហើយស្វែងរកការងារធ្វើ | **ហានិភ័យ**: មិនស្គាល់នរណា ប្រឈមនឹងការជួញដូរ<br>**ផលប្រយោជន៍**: ក៏អាចទៅរួចក្នុងការបានលុយភ្លាមៗ | យកទូរស័ព្ទទៅជាមួយ ទៅជាមួយមិត្តភក្តិ | ? |
| | | **ជំរើសទី២**<br>រងចាំទាល់តែសន្សំលុយបានសិនហើយរៀបចំការងាររួចរាល់ | **ហានិភ័យ**: បាត់បង់ឱកាសប៉ុន្តែប្រឈមនឹងការជួញដូរតិច<br>**ផលប្រយោជន៍**: ការងារល្អ ហានិភ័យតិច មានជម្រើសច្រើន | បន្តការស្វែងរកទៀត | |
| | | **ជំរើសទី៣**<br>មិនទៅ | **ហានិភ័យ**: នៅតែក្រ<br>**ផលប្រយោជន៍**: គ្មានការជួញដូរ | បន្តការសិក្សាជំនាញនៅផ្ទះដែលអាចជួយដល់អនាគតបាន | |

# ១៩ IS ១៩គ ៖ ករណីសិក្សាអំពីការសម្រេចចិត្ត

### រឿងទី ១

ន មកពីសមាជិកគ្រួសារធំមួយ ។ នាងរស់នៅជាមួយឪពុកម្ដាយនាង យាយតា និងបងប្អូនប្រុសស្រីទាំងបួននាក់របស់នាង។ ថ្ងៃមួយន បានទៅតៀមកាហ្វេមួយកន្លែងនៅក្នុងទីប្រជុំជន នៅពេលនោះមានមនុស្សម្នាក់បានណែនាំខ្លួនគេឲ្យនាងស្គាល់។ បុរសនោះនិយាយថា គេធ្វើការនៅក្នុងរោងចក្រមួយនៅភាគខាងត្បូងនៃប្រទេស ហើយគេអាចជួយនាងឲ្យបានចូលធ្វើការជាអ្នកកាត់ដេរនៅទីនោះ។ បុរសនោះប្រាប់ន ថានាងទទួលបានប្រាក់កម្រៃមធ្យមេ ហើយនាងត្រូវស្វែងរកកន្លែងស្នាក់នៅដោយខ្លួនឯង។ គេបានឲ្យលេខទូរស័ព្ទរបស់គេទៅនាង។ ន មានបងប្អូនជីដូនមួយម្នាក់រស់នៅក្នុងក្រុងនោះដែរ ដូច្នេះ នៅពេលដែលនាងបានការងារធ្វើ គឺនាងអាចស្នាក់នៅជាមួយគ្នាបាន។ នាងបានបញ្ចប់វិទ្យាល័យហើយ ប៉ុន្តែមិនអាចរកការងារធ្វើនៅក្នុងមូលដ្ឋានខ្លួនបាន។ នាងចង់ ទ្រទ្រង់ខ្លួនឯង និងចង់សន្សំប្រាក់ខ្លះដើម្បីផ្ញើត្រឡប់ទៅឲ្យឪពុកម្ដាយនាង។ ន ព្យាយាម ធ្វើការសម្រេចចិត្ត ថាតើនាងគួរយល់ព្រមជាមួយមេខ្យល់ម្នាក់នោះ ឬយ៉ាងណា។

### រឿងទី ២

ឧ មកពីគ្រួសារក្រីក្រមួយ។ គេគឺជាកូនតែម្នាក់គត់ក្នុងគ្រួសារដែលបានទៅសាលារៀន។ គេទទួលបានពិន្ទុល្អនៅសាលា ហើយលោកគ្រូ អ្នកគ្រូរបស់គេចូលចិត្តគេណាស់។ ឪពុកម្ដាយរបស់គេខិតខំធ្វើការងារខ្លាំងណាស់ ប៉ុន្តែមិនសូវបានប្រាក់ច្រើនសោះ។ ឧ ពិតជាចង់ជួយដល់គ្រួសារគេដោយការរកប្រាក់បន្ថែម។ ឧ បានបញ្ឈប់ការសិក្សាមួយឆ្នាំ មុនពេលការបញ្ចប់ថ្នាក់របស់ខ្លួន។ គេព្យាយាមសម្រេចចិត្តថា តើគេគួរតែបោះបង់ចោលការសិក្សាដើម្បីធ្វើការងារនៅការដ្ឋានសំណង់មួយក្នុងមូលដ្ឋានរបស់ខ្លួន ឬយ៉ាងណា។

# ២០ មេរៀនទី២០ ÷ សិក្សាបន្ថែម

មេរៀននេះជួយឲ្យអ្នកអនុវត្ត "ជំហានទី២ ៖ ការសិក្សាបន្ថែម" នៃគំរូការធ្វើសេចក្តីសម្រេចចិត្ត

## វត្ថុបំណង

អ្នកចូលរួម នឹងរិះរកមធ្យោបាយក្នុងការសិក្សាបន្ថែម អំពីការធ្វើចំណាកស្រុក ដោយការសួរសំណួរ ដើម្បីធ្វើការសម្រេចចិត្តត្រូវគ្រប់ជ្រុងជ្រោយ ។

## ពេលវេលា

៧៥ នាទី

## សម្ភារៈ

- ក្រដាសផ្ទាំងធំមួយចំនួន និងប៊ិច
- ថតចម្លងច្រើនច្បាប់នូវ"ទ.ស២០ក៖ការសួរសំណួរ"សម្រាប់អ្នកចូលរួមគ្រប់រូប(ក្រុមនឹងបែងចែកជាគូដើម្បីប្រើឯកសារនេះនៅក្នុងម៉ោងសិក្សានេះ ហើយអ្នកចូលរួមម្នាក់ត្រូវការមួយច្បាប់សម្រាប់ មេរៀនបន្ទាប់)
- កូនសៀវភៅនាវិកវៃឆ្លាត

## សេចក្តីផ្តើម

**ការស្វាគមន៍**

ស្វាគមន៍អ្នកចូលរួមដោយហៅឈ្មោះ។ ហុចតៗគ្នានូវបញ្ជីចុះវត្តមាន។

**សកម្មភាពមុនចាប់ផ្តើម**

ឲ្យអ្នកសម្របសម្រួលជាយុវជនដឹកនាំល្បែងថាមពលនៅក្នុងតារាង។

**ការរំឭកមេរៀន**

តើមាននរណាបានបំពេញក្នុង គំរូនៃការសម្រេចចិត្តកាលពីសប្តាហ៍មុនដែរ ឬទេ? ប្រសិនបើមាន សួរថា តើមាននរណាចង់ចែករំលែកអ្វីដែលគេបានធ្វើដែរ ឬទេ។

## ការសិក្សាបន្ថែម

សួរថា តើមាននរណាអាចរៀបរាប់បានអំពីជំហានទាំង ៥ នៃគំរូនៃការសម្រេចចិត្តបានដែរឬទេ។ ជំហានទាំងនោះរួមមាន ៖

- ជំហានទី ១ ៖ បរិយាយការសម្រេចចិត្តរបស់អ្នកជាអ្នកសួរសំណួរមួយ។
- ជំហានទី ២ ៖ សិក្សាបន្ថែម។
- ជំហានទី ៣៖ រៀបរាប់ពីជម្រើសផ្សេងទៀត។
- ជំហានទី ៤ ៖ វាយតម្លៃហានិភ័យ និងអត្ថប្រយោជន៍។
- ជំហានទី ៥ ៖ ធ្វើការសម្រេចចិត្តរបស់អ្នក។

ឲ្យអ្នកចូលរួម ( សិស្ស ) យក កូនសៀវភៅនាវិកវៃឆ្លាត និងមើលត្រង់ចំណុចស្តីពីគំរូនៃការសម្រេចចិត្ត។

ពន្យល់ថា នៅក្នុងមេរៀនចំនួន ពីរបន្ទាប់ទៀត ពួកគេនឹងសិក្សាអំពីរបៀបប្រមូលព័ត៌មានដែលនឹងជួយឲ្យគេបំពេញគំរូនៃការសម្រេចចិត្តបាន។

## តើយើងត្រូវការសិក្សាអំពីអ្វី? សរសេរសំណួររបស់យើង

ចែកអ្នកចូលរួមបួនក្រុម។ ឲ្យក្រដាសផ្ទាំងធំមួយសន្លឹក និងប៊ិចដល់ក្រុមនីមួយៗ។ ឲ្យអ្នកចូលរួមគិតពីសំណួរដែលគេចង់ដឹងចម្លើយ ប្រសិនបើគេត្រូវធ្វើចំណាកស្រុក។ ក្រុមនឹងត្រូវផ្ដោតជាសំខាន់លើសំណួរដែលពាក់ព័ន្ធនឹងផ្នែកខុសៗគ្នានៃការធ្វើចំណាកស្រុក។ ក្រុមនឹងត្រូវផ្ដោតការយកចិត្តទុកដាក់លើប្រធានបទដូចខាងក្រោម ៖

- ក្រុមទី ១៖ សំណួរពាក់ព័ន្ធនឹង **របៀបរស់នៅក្នុងប្រទេស / កន្លែងគោលដៅ**
- ក្រុមទី ២៖ សំណួរពាក់ព័ន្ធនឹង**ការធ្វើដំណើរ** (មធ្យោបាយទៅដល់កន្លែងគោលដៅ មធ្យោបាយត្រឡប់មកវិញ មធ្យោបាយធ្វើដំណើរទៅនេះទៅនោះនៅពេលអ្នកទៅដល់)
- ក្រុមទី ៣៖ សំណួរ**ពាក់ព័ន្ធនឹងការងារ**
- សំណួរពាក់ព័ន្ធនឹង**ឯកសារពាក់ព័ន្ធ**។

១០ នាទីក្រោយមក ឲ្យក្រុម ចែករំលែកសំណួររបស់គេ។ សួរថាតើក្រុមមានសំណួរអ្វីចង់បន្ថែមដែរឬទេ? គេចង់បន្ថែម ទៅនឹងការរៀបរាប់ របស់ក្រុមទៀតដែរឬ ទេ។ ចូរបន្ថែមប្រសិនបើគេមាន។

បន្ទាប់មកទៀត ឲ្យសិស្សគិតអំពីមនុស្សនៅក្នុងសហគមន៍របស់គេដែលអាចឆ្លើយសំណួរទាំងនេះបាន។ ការរៀបរាប់ទាំងនេះអាចរួមមាន ៖

- មនុស្សដែលធ្លាប់ធ្វើចំណាកស្រុកពីមុន
- អាជ្ញាធរមូលដ្ឋាន
- អ្នករកការងារឲ្យធ្វើ
- បុគ្គលិកអង្គការ មិនមែនរដ្ឋាភិបាល

ពន្យល់ថា ក្រុមនឹងត្រូវទៅចុះទៅជួបផ្ទាល់ជាមួយនឹងសមាជិកសហគមន៍ដើម្បីសិក្សាបន្ថែមអំពីការធ្វើចំណាកស្រុក។ សួរទៅអ្នកចូលរួមថា តើគេមានស្គាល់នរណាម្នាក់នៅក្នុងបញ្ជីរៀបរាប់នេះដែលនឹងមានឆន្ទៈក្នុងការជជែកជាមួយក្រុមដែរ ឬទេ។ ប្រសិនបើមាន រកវិធីដើម្បីទំនាក់ទំនងទៅកាន់បុគ្គលនោះ។ អ្នកសម្របសម្រួលគួរមានការស្រាវជ្រាវអំពីមនុស្សនៅក្នុងសហគមន៍ដែលអាចមានឆន្ទៈក្នុងការជជែកឆ្លើយសំនួរជាមួយនឹងសិស្សផងដែរ។

សុំអ្នកស្ម័គ្រចិត្តម្នាក់ពីក្រុមនីមួយៗ ដើម្បីសរសេរសំណួរទាំងអស់ឲ្យស្អាតនៅលើក្រដាសដែលគេអាចយកទៅតាមនៅពេលដែលពួកគេទៅជួបជាមួយ នឹងបុគ្គលក្នុងសហគមន៍។ ប្រមូលក្រដាសសំណួរពីអ្នកចូលរួម ថតចម្លងសម្រាប់អ្នកចូលរួមម្នាក់ៗនៅក្នុងក្រុមមុនពេលមេរៀនក្រោយទៀត ដើម្បីគេអាចប្រើប្រាស់វាជាឯកសារយោងនៅពេលដែលគេទៅជួបជាមួយនឹងបុគ្គលនោះ។

## អនុវត្តការសួរសំណួរ

បែងចែកក្រុមមានគ្នាពីរនាក់ ។ ឲ្យក្រុមនីមួយៗនូវច្បាប់ថតចម្លងមួយច្បាប់នៃ "IS ២០ក៖ការសួរសំណួរ"។ ឲ្យអ្នកស្ម័គ្រចិត្តអានទម្រង់ឲ្យឮ។

បន្តទៅទៀត ឲ្យក្រុមមានគ្នាពីរនាក់នោះហ្វឹកហាត់ការសួរសំណួរគ្នាទៅវិញទៅមកអំពីការធ្វើចំណាកស្រុក ដោយប្រើប្រាស់ព័ត៌មានអំពីរបៀបសួរសំណួរ។

## ការសម្តែងរឿង

ឲ្យអ្នកចូលរួមបែងចែកក្រុមមានគ្នាពី ៨-១២ នាក់។ ឲ្យក្រុមនីមួយៗរៀបចំត្រៀមសម្តែងរឿង។ (ប្រសិនបើមានក្រុមលើសពីពីរក្រុម គេអាចប្រើរឿងខាងក្រោមពីរដងបាន)។

ក្រុមទី១៖មានមិត្តភក្តិពីរនាក់។ម្នាក់បានមកជួបម្នាក់ទៀតដើម្បីសុំយោបល់។គាត់បានទទួលការងារធ្វើនៅរោងចក្រកែរច្នៃត្រីខកំប៉ុងមួយនៅប្រទេសផ្សេង។ ប្រាក់ខែគឺខ្ពស់ខ្លាំងណាស់។ គាត់គិតបោះបង់ចោលការសិក្សា។ ហើយខ្ចីប្រាក់គេ ៣០០ ដុល្លារដើម្បីបង់ឲ្យមេខ្យល់ ដើម្បីទទួលបានការងារនោះធ្វើ។ តើយោល់អ្វីខ្លះដែលអ្នកនឹងផ្តល់ឲ្យទៅគាត់?

ក្រុមទី ២ ៖ មានមិត្តភក្តិពីរនាក់។ ម្នាក់បានមកជួបម្នាក់ទៀតដើម្បីសុំយោបល់។ នាងបានឃើញគេផ្សាយពាណិជ្ជកម្មមួយ នៅលើកាសែតការងារមួយនៅក្នុងរោងចក្រកាត់ដេរ។ ប្រាក់ខែគឺ ខ្ពស់ខ្លាំងណាស់។ នាងមិនចេះដេរទេ ប៉ុន្តែការផ្សាយពាណិជ្ជកម្មនោះថា មិនចាំបាច់មានជំនាញអ្វីក៏បាន។ ការផ្សាយពាណិជ្ជកម្មនោះ មិនបានផ្តល់នូវព័ត៌មាន អំពីទីតាំងកន្លែងការងារនោះទេ ហើយគេគ្រាន់តែដាក់លេខទូរស័ព្ទរបស់មេខ្យល់ប៉ុណ្ណោះ។ តើយោល់អ្វីខ្លះដែលអ្នកនឹងផ្តល់ឲ្យទៅនាង ?

ប្រាប់ក្រុមឲ្យបង្កើតជាការសម្តែងរឿងរយៈពេលប្រាំនាទី ហើយបន្ទាប់មកសម្តែងតាមក្រុមនីមួយៗ។

### សង្ខេបមេរៀន

- គំរូនៃការសម្រេចចិត្ត អាចជួយដល់អ្នក ឲ្យធ្វើសេចក្តីសម្រេចចិត្តថា តើគួធ្វើចំណាកស្រុក ឬមិនគួរ។
- ជំហានទី ២ អំពីគំរូនៃការសម្រេចចិត្តគឺ "ការសិក្សាបន្ថែម" ។
- អ្នកប្រហែលជាចង់សិក្សាបន្ថែមអំពី របៀបរស់នៅកន្លែងគោលដៅ មធ្យោបាយទៅដល់កន្លែងនោះ មធ្យោបាយត្រឡប់មកវិញ ប្រភេទការងារដែលមាននៅទីនោះ និងឯកសារណាខ្លះ ដែលអ្នកត្រូវការដើម្បីទៅដល់ទីនោះ។
- មនុស្សខាងក្រោមនេះប្រហែលជាអាចឆ្លើយសំណួររបស់អ្នកបានអំពីការធ្វើចំណាកស្រុក ៖
  - មនុស្សដែលធ្លាប់ធ្វើចំណាកស្រុកពីមុន
  - អជ្ញាធរមូលដ្ឋាន
  - អ្នករកការងារឲ្យធ្វើ
  - បុគ្គលិកអង្គការ មិនមែនរដ្ឋាភិបាល

## ការបិទវគ្គ

ប្រាប់ឲ្យអ្នកចូលរួមសរសេរ ឬសួរសំណួរ ឬផ្តល់ជាព័ត៌មានត្រឡប់ និងប្រគល់ឲ្យទៅអ្នកសម្របសម្រួលដោយមិនបាច់បញ្ចេញឈ្មោះ។

អរគុណដល់អ្នកចូលរួមទាំងអស់គ្នា ដែលបានមកចូលរួម។ បញ្ជាក់ឡើងវិញអំពីការប្រជុំក្លិបពេលក្រោយ។ ប្រាប់ពួកគេថា ពួកគេទទួលបានផ្កាយមួយទៀតសម្រាប់ការចូលរួមក្នុងមេរៀននេះ។ ពន្យល់ថា អ្នកនឹងរៀបចំការប្រជុំក្លិបមួយដើម្បីសួរសំណួរ និងបន្ទាប់មកទំនាក់ទំនងទៅកាន់អ្នកចូលរួមដើម្បីបញ្ជាក់ពីពេលវេលា និងទីកន្លែង។

# ២០ IS ២០ក ÷ ការសួរសំណួរ

គោលការណ៍ណែនាំទាំងនេះត្រូវតែអនុវត្តតាមដោយយុវជនរបស់ SNYC នៅពេលដែលពួកគេនិយាយទៅកាន់មនុស្សដែលដឹងអំពីការធ្វើចំណាកស្រុក (ខាងក្រោមនេះហៅថា អ្នកឆ្លើយសម្ភាសន៍)។

## ដំណាក់កាលរៀបចំ

**ត្រូវមានការទទួលខុសត្រូវចំពោះពេលវេលា**

- គិតអំពីពេលវេលាដែលល្អបំផុតដើម្បីសួរអ្នកឆ្លើយសំភាសន៍ ដែលអាចផ្តល់ការសំភាសន៍ជាមួយក្រុម។ ឧទាហរណ៍ថា មិនត្រូវសម្ភាសន៍ នៅពេលដែលគាត់កំពុងធ្វើការអោយគេពីព្រោះ វាអាចធ្វើអោយគាត់មានបញ្ហាជាមួយថៅកែ។ មិនត្រូវសួរអ្នកឆ្លើយសំភាសន៍ពេលគាត់ទើបត្រឡប់មកពីស្រែនឿយហត់នោះទេ។

## គោលការណ៍ក្រមសីលធម៌

**ការពារអ្នកផ្តល់សម្ភាសន៍ពីសំនួរដែលធ្វើឲ្យប៉ះពាល់អារម្មណ៍**

- មិនត្រូវសួរអ្នកឆ្លើយសម្ភាសន៍ពីបទពិសោធន៍ស្លាកស្នាមទូរយសឡើយ។
- មិនត្រូវសម្ភាសន៍យុវវ័យទេ។

**ការពារអ្នកចូលរួមរបស់ SNYC**

- មិនត្រូវ ណាត់ជួបជាមួយអ្នកឆ្លើយសម្ភាសន៍ណាដែលអាចនឹងមានការខឹងទៅនឹងសំណួរដែល អ្នកសួរឡើយ។ (ឧទាហរណ៍ មិនត្រូវសួរបុគ្គលណាដែលទំនងជាអ្នកជួញដូរមនុស្សឡើយ)។
- មិនត្រូវទុកក្មេងនៅតែឯងនៅក្នុងបន្ទប់ជាមួយមនុស្សធំឡើយ។

**អ្នកចូលរួមទាំងអស់ត្រូវតែជាអ្នកស្ម័គ្រចិត្ត**

- ផ្តល់ដំណឹងទៅបុគ្គល ដែលអ្នកនឹងទៅជួបផ្ទាល់ពីមូលហេតុដែលអ្នកនឹងទៅ នរណាខ្លះនឹងទៅ និងប្រធានបទនៃសំណួររបស់អ្នក។
- អ្នកចូលរួមរបស់ SNYC មិនចាំបាច់ចូលរួមទេ ប្រសិនបើគេមិនចង់នោះ។

**គោរពចំពោះអ្នកឆ្លើយសម្ភាសន៍**

- សម្តែងអាកប្បកិរិយាដោយការគោរពចំពោះបុគ្គលដែលឆ្លើយសំណួររបស់អ្នក។

**ជៀសវាងការរំពឹងទុកដែលមិនពិតប្រាកដ**

- អ្នកដែលឆ្លើយសំណួររបស់អ្នកគួរដឹងថា គាត់នឹងមិនទទួលបានប្រាក់ ឬអត្ថប្រយោជន៍អ្វីផ្សេងទៀតឡើយក្រៅពីការចូលរួមនេះ ។

**វក្យាការសម្ងាត់**

- មិនត្រូវដាក់ឈ្មោះទេ ពេលអ្នកសរសេរចម្លើយ។ មិនត្រូវប្រាប់ពីឈ្មោះរបស់អ្នកឆ្លើយសម្ភាសន៍ទៅអ្នកដែលនៅក្រៅពីក្រុមរបស់អ្នកឡើយ។
- ក្រើនរំឭកដល់អ្នកចូលរួមរបស់ SNYC មិនត្រូវនិយាយពីក្រោយខ្នង នូវអ្វីដែលអ្នកឆ្លើយសម្ភាសន៍ បានប្រាប់ដល់អ្នកឡើយ។

## បច្ចេកទេសល្អៗក្នុងការសួរសំណួរ

**ត្រូវចេះគួរសម**

- និយាយអរគុណចំពោះអ្នកឆ្លើយសម្ភាសន៍សម្រាប់ការចំណាយពេលរបស់គាត់។

**មិនត្រូវវិនិច្ឆ័យរកខុសត្រូវ**

- មិនត្រូវប្រើពាក្យសម្តីវិនិច្ឆ័យរកខុសត្រូវចំពោះចំលើយរបស់អ្នកផ្តល់សំភាសន៍ឡើយ។

**ត្រូវធ្វើជាអ្នកស្តាប់ដ៏សកម្ម និងមានភាពបទបែន**

- ត្រូវបង្ហាញពីការយល់ចិត្តចំពោះអ្នកផ្តល់សម្ភាសន៍ និងចាប់អារម្មណ៍ក្នុងការយល់អំពីទស្សនៈ របស់គាត់។
- អនុញ្ញាតិឲ្យអ្នកផ្តល់សម្ភាសន៍និយាយឲ្យបានច្រើនតាមដែលអាចធ្វើនៅបាន
- គិតអំពីអ្វីដែលគេកំពុងនិយាយ និងសួរសំណួរបញ្ជាក់បន្ថែម។

**សួរសំណួររំឭកឡើងវិញ**

- សួរសំណួររំឭកឡើងវិញ ប្រសិនបើអ្នកផ្តល់សម្ភាសន៍ បាននិយាយពីអ្វីដែលគួរឲ្យចាប់អារម្មណ៍ រឺអ្វីដែលអ្នកមិនយល់ ឬអ្វីដែលអ្នកចង់ដឹងបន្ថែមទៀត។

**កត់ត្រាទុកឲ្យបានល្អ**

- កត់ត្រាទុកអ្វីគ្រប់យ៉ាង ដែលអ្នកផ្តល់សម្ភាសន៍បាននិយាយ។ ពិនិត្យកំណត់ត្រារបស់អ្នកជាមួយ ក្រុមដើម្បីបញ្ជាក់ច្បាស់លាស់អំពីចម្លើយដែលអ្នកទទួលបាន។

**ជៀងម៉ោង**

- ព្យាយាមសួរសំណួរទាំងអស់ ប៉ុន្តែមិនត្រូវទុកឲ្យការពិភាក្សាយូរជាងមួយម៉ោងឡើយ។

មេរៀននេះតពីមេរៀនទី ២០ ដោយផ្តោតសំខាន់លើ "ជំហានទី២ ៖ ការសិក្សាបន្ថែម" នៃគំរូការធ្វើសេចក្តីសម្រេចចិត្ត ។

## វត្ថុបំណង

អ្នកចូលរួមអនុវត្តជំនាញស្វែងរកព័ត៌មាន និងជំនាញសម្ភាសន៍ដើម្បីសិក្សាបន្ថែមអំពីការធ្វើចំណាកស្រុកដើម្បីធ្វើការសម្រេចចិត្តត្រូវគ្រប់ជ្រុងជ្រោយ ។

## ពេលវេលា

៧៥ នាទី

## សម្ភារៈ

- ថតចម្លងសំនួរ សំរាប់អ្នកចូលរួម ម្នាក់១សន្លឹក ដែលក្រុមបានសរសេរ ក្នុងអំឡុងពេលរៀនមេរៀនមុន។
- ថតចម្លង "IS ២០ក ៖ ការសួរសំណួរ" ពីមេរៀនមុន សម្រាប់អ្នកចូលរួមទាំងអស់គ្នា

## ការរៀបចំគ្រៀម

អ្នកសម្របសម្រួលគួរមាន ការណាត់ជួបជាមួយ អ្នកដែលដឹងអំពីការ ធ្វើចំណាកស្រុក ឲ្យបានមុនការប្រជុំក្លិប (ដូចដែលបរិយាយកាលពីមេរៀនមុន)។ បុគ្គលនោះគួរជាអ្នកដែលអាចនិយាយបានអំពីការធ្វើចំណាកស្រុកប៉ុន្តែមិនគួរជាការធ្វើចំណាកស្រុកប្រថុយប្រថានប្រកបដោយគ្រោះថ្នាក់ទេ។

ប្រសិនបើបុគ្គលម្នាក់នោះមិនអាច មកកាន់ទីតាំងក្លិបយុវវ័យរបស់ SNYC បាននោះអ្នកចូលរួមអាចទៅជួបជាមួយគាត់ដោយផ្ទាល់បាន។

ប្រសិនបើការផ្តល់សំភាសន៍ នឹងត្រូវធ្វើខុសពីពេលប្រជុំក្លិបធម្មតារបស់អ្នក នោះត្រូវទូរស័ព្ទផ្ញើសារ ឬទៅជួបផ្ទាល់ជាមួយអ្នកចូលរួមរបស់ SNYC ដើម្បីជូនដំណឹងពួកគេអំពីការណាត់ជួបនេះ។

មួយថ្ងៃមុនការសំភាសន៍ ទូរស័ព្ទទៅអ្នកផ្តល់សម្ភាសន៍ថា អ្នកនឹងជួបជាមួយគាត់ ហើយរំឭកដល់គាត់ថាអ្នកនឹងទៅជួបផ្ទាល់។

កុំភ្លេចថតចម្លងសំណួររបស់អ្នកចូលរួមសម្រាប់សមាជិកក្រុមនីមួយៗ និងយកសំណួរទាំងនោះទៅកន្លែងប្រជុំ។

## សេចក្តីផ្តើម

### ការស្វាគមន៍

ស្វាគមន៍អ្នកចូលរួមដោយហៅឈ្មោះ។ ហុចតៗគ្នានូវបញ្ជីវត្តមាន។

### សកម្មភាពមុនចាប់ផ្តើម

គ្មានសកម្មភាពចាប់ផ្តើមមុនទេថ្ងៃនេះ។

### ការរំឭកមេរៀន

មុនពេលអ្នកចូលរួម ជួបជាមួយនឹងអ្នកផ្តល់សម្ភាសន៍ ឲ្យពួកគេអានសំណួររបស់គេឡើងវិញម្តងទៀត។ អាន "IS ២១ក ៖ ការសួរសំណួរ" ឲ្យឮៗទៅកាន់ក្រុម។

## ការសួរសំណួរ

កាលពីមេរៀនមុន អ្នកចូលរួមបានគិតអំពីសមាជិកសហគមន៍ដែលអាចឆ្លើយសំណួររបស់គេពាក់ព័ន្ធនឹងការធ្វើចំណាកស្រុកបាន។ នៅក្នុងមេរៀននោះ គេបានរៀបចំតារាងឈ្មោះ មនុស្សមួយក្រុមដែលអាចដឹងអំពីការធ្វើចំណាកស្រុក និងតារាងសំណួរដែលគេចង់សួរទៅអ្នកទាំងនោះ។ យ៉ាងហោច ២០នាទីមុនទៅជួបជាមួយនឹងអ្នកដែលដឹងអំពីការធ្វើចំណាកស្រុក អ្នកសម្របសម្រួលគួរជួបជាមួយអ្នកចូលរួមដើម្បីត្រួតពិនិត្យម្តងទៀត (ដូចខាងលើ)។

អាន "IS ២០ក ៖ ការសួរសំណួរ" ទៅកាន់អ្នកចូលរួម។ ចែកឲ្យគេនូវឯកសារថតចម្លងម្នាក់មួយច្បាប់នៃសំណួរដែលពួកគេបានសរសេរកាលពីសប្តាហ៍មុន។

នៅក្នុងការធ្វើសម្ភាសន៍ អ្នកចូលរួមនឹងសួរសំណួរខ្លួនឯង ស្របតាមគោលការណ៍ណែនាំអំពី "IS ២០ក ៖ ការសួរសំណួរ"។

ប៉ុន្តែអ្នកសម្របសម្រួល ក៏ត្រូវការពារសុវត្ថិភាពបុគ្គល ដែលពួកគេនិយាយជាមួយផងដែរ។ ប្រសិន បើអ្នកចូលរួមសួរសំណួរណាដែលធ្វើឲ្យបុគ្គលនោះមានអារម្មណ៍មិនស្រួល ឬក្រៀមក្រំនោះ អ្នកសម្របសម្រួលគួរផ្តល់យោបល់ដោយទន់ភ្លន់ថា ប្អូនត្រូវបន្តទៅសំណួរបន្ទាប់ទៀតចុះ ។ ការសម្ភាសន៍គួរមានរយៈពេលត្រឹមពី ៣០នាទី ដល់១ម៉ោងប៉ុណ្ណោះ។ មិនត្រូវទុកឲ្យការពិភាក្សាមានរយៈពេលយូរជាងមួយម៉ោងឡើយ។

វាអាចជាការមានប្រយោជន៍ល្អបំផុតសម្រាប់យុវជនក្នុងការរៀនសូត្រពីមនុស្ស ដែលមានបទពិសោធន៍ក្នុងការធ្វើចំណាកស្រុកពិតប្រាកដ។ ដូច្នេះ ប្រសិនបើនៅសល់ពេល ក្រុមអាចធ្វើការសម្ភាសន៍លើសពីម្នាក់ក្នុងមធ្យោបាយនេះ។

កុំភ្លេចនិយាយអរគុណ ទៅកាន់បុគ្គលដែល បានឆ្លើយសំណួរ ចំពោះការចំណាយពេលវេលារបស់គាត់ដើម្បីជជែកជាមួយក្រុម។

# ២២ មេរៀនទី២២ ៖ ការប្រើប្រាស់បញ្ជីត្រួតពិនិត្យ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព

## វត្ថុបំណង

អ្នកចូលរួមនឹងយល់អំពីរបៀបធ្វើផែនការ សម្រាប់ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និង អាចកំណត់ពីជម្រើសផ្សេងសម្រាប់ការធ្វើចំណាកស្រុក ដើម្បីរក្សាខ្លួនគេឲ្យមានសុវត្ថិភាព

## ពេលវេលា

៧៥ នាទី

## សម្ភារៈ

- កូនសៀវភៅស្តីពីការចង្អុលបង្ហាញជំនាញជីវិត
- ឯកសារយោង "IS ២២ក ៖ បញ្ជីត្រួតពិនិត្យសម្រាប់ការធ្វើចំណាកស្រុកដោយសុវត្ថិភាព"

## សេចក្តីផ្តើម

**ការស្វាគមន៍**

ស្វាគមន៍អ្នកចូលរួមដោយហៅឈ្មោះ។ ហុចតៗគ្នានូវបញ្ជីវត្តមាន។

**សកម្មភាពមុនចាប់ផ្តើម**

ឲ្យអ្នកសម្របសម្រួលជាយុវជនដឹកនាំល្បែងថាមពលនៅក្នុងតារាង។

**ការរំឭកមេរៀន**

តើអ្នកមានការរំភើបនូវអ្វីដែលអ្នកបានសិក្សានៅក្នុងការធ្វើសម្ភាសន៍ដែរ ឬទេ?

តើអ្នកនឹងប្រើប្រាស់ព័ត៌មានទាំងនេះនៅក្នុងជីវិតពិតរបស់អ្នកដែរ ឬទេ?

តើអ្នកអាចគិតអំពីអ្នកដទៃដែលអ្នកអាចសួរសំណួរអំពីការធ្វើចំណាកស្រុកដែរ ឬទេ?

## តារាងត្រួតពិនិត្យនៃការធ្វើចំណាកស្រុកដោយសុវត្ថិភាព

ពន្យល់ថាតារាងត្រួតពិនិត្យគឺដើម្បីជួយដល់អ្នកចូលរួមឲ្យធ្វើផែនការសម្រាប់ការធ្វើចំណាកស្រុកដោយសុវត្ថិភាព។

ឲ្យអ្នកចូលរួមបើកកូនសៀវភៅនារិកវៃឆ្លាត និងបើកទៅផ្នែកនិយាយអំពី "តារាងត្រួតពិនិត្យ ៖ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព"។ សុំអ្នកស្ម័គ្រចិត្តម្នាក់ឡើងអានឲ្យ ឮៗ។

ពន្យល់ថា គេនឹងមិនត្រូវបំពេញតារាងត្រួតពិនិត្យទេក្នុងមេរៀននេះ។ តារាងនេះត្រូវបានរៀបចំឡើងដើម្បីជួយនៅពេលដែលគេរៀបចំផែនការដើម្បីធ្វើចំណាកស្រុក។ នេះមានន័យថា ប្រសិនបើគេមានផែនការធ្វើចំណាកស្រុក គេគួរតែបំពេញតារាងនេះមុនពេល គេធ្វើចំណាកស្រុក។

បន្ទាប់មកទៀត សួរអ្នកចូលរួមថា

- តើមានសំណួរដែលអ្នកមិនយល់ដែរ ឬទេ?
- តើសំណួរទាំងនេះអាចជួយដល់អ្នកក្នុងការត្រៀមរៀបចំធ្វើចំណាកស្រុកដែរ ឬទេ?
- តើមានឧបស័គ្គអ្វីខ្លះដែលអាចកើតមានចំពោះការប្រើប្រាស់ តារាងត្រួតពិនិត្យនេះ ឬទេ?
- តើយើងអាចជម្នះឧបស័គ្គទាំងនេះបានដោយរបៀបណា?

- តើអ្នកអាចរកព័ត៌មានមកបំពេញសំណួរទាំងនេះនៅកន្លែងណា?
- តើអ្នកអាចរកព័ត៌មានពីអ្នកធ្វើចំណាកស្រុកពីមុន អាជ្ញាធរមូលដ្ឋាន លោកគ្រូ/អ្នកគ្រូ បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលបានដែរ ឬទេ?
- តើអ្នកនឹងចែករំលែកតារាងត្រួតពិនិត្យនេះជាមួយក្រុមគ្រួសាររបស់អ្នកដែរ ឬទេ?

## តើមានអ្វីកើតឡើងប្រសិនបើខ្ញុំមិនអាចរកព័ត៌មានអំពីតារាងត្រួតពិនិត្យនេះបាន?

### ប្រសិនបើអ្នករកមិនបានព័ត៌មានខ្លះ:

ពន្យល់ថា តារាងត្រួតពិនិត្យនេះមានន័យថា ជាការណែនាំមួយ។ អ្នកអាចនឹង មិនបានគ្រប់ព័ត៌មានទាំងអស់ដើម្បីមកបំពេញតារាងត្រួតពិនិត្យនេះទេមុនពេលអ្នកចាកចេញ។ ប៉ុន្តែបើឆ្លើយសំណួរនៅលើតារាងត្រួតពិនិត្យនេះបានកាន់តែច្រើន គឺអ្នកនឹងកាន់តែមានសុវត្ថិភាព។

### ប្រសិនបើអ្នកមិនអាចរកបានព័ត៌មានភាគច្រើន ឬមិនបានទាំងអស់

ប្រសិនបើអ្នកមិនអាចរកបានព័ត៌មានភាគច្រើន ឬមិនបានទាំងអស់អំពីតារាងត្រួតពិនិត្យនេះនោះ គឺជាសញ្ញាព្រមានមួយដែលថា អ្នកកំពុងស្ថិតក្នុងហានិភ័យនៃការជួញដូរកាន់តែច្រើនហើយ។
ប្រើលក្ខខ័ណ្ឌដែលបានពិភាក្សានៅក្នុង គំរូនៃការសម្រេចចិត្តនោះគឺ ហានិភ័យមានច្រើនជាងអត្ថប្រយោជន៍។
ប្រសិនបើអ្នកមិនអាចរកបានព័ត៌មានភាគច្រើន អ្នកគួរពិចារណាអំពីជម្រើសផ្សេងទៀតចំពោះការធ្វើចំណាកស្រុកវិញ។

## ជម្រើសផ្សេងទៀតសម្រាប់ការធ្វើចំណាកស្រុក

ប្រាប់អ្នកចូលរួមថា នៅពេលដែលគេធ្វើសេចក្ដីសម្រេចចិត្តថា តើត្រូវធ្វើចំណាកស្រុក ឬយ៉ាងណានោះពេលខ្លះវាពិបាកក្នុងការគិតពីជម្រើសផ្សេងទៀតណាស់។ ប្រាប់ទៅក្រុមថាវាអាចមានប្រយោជន៍ ក្នុងការគិតអំពីជម្រើសដូចខាងក្រោម (អានជម្រើសនេះឲ្យ ឮៗទៅកាន់ក្រុម)៖

### ពន្យារពេលការធ្វើចំណាកស្រុក

សួរខ្លួនឯងថា តើអ្នកត្រូវបានបង្ខំដោយកាលៈទេសៈក្នុងជីវិតឲ្យធ្វើចំណាកស្រុកឬយ៉ាងណា។ ប្រសិនបើមិនមានទេ វាអាចជាជម្រើសឆ្លាតវៃក្នុងការពន្យារពេលក្នុងការធ្វើចំណាកស្រុក។
រង់ចាំរហូតទាល់តែអ្នកមានអាយុលើស ១៦ ឆ្នាំ។ នៅក្នុងប្រទេសជាច្រើន វាជាការខុសច្បាប់ចំពោះ ការធ្វើការងារពេញម៉ោងប្រសិនបើអ្នកមានអាយុក្រោម ១៦ ឆ្នាំ។ ជាមួយគ្នានេះដែរ ប្រសិន បើអ្នករង់ចាំទាល់តែអ្នកធំបន្តិច អ្នកនឹងដឹងកាន់តែច្រើនអំពីពិភពលោក និងក្លាយជាបុគ្គលដែលឆ្លាតវៃ និងរឹងមាំជាងមុន។ ប្រសិនបើអ្នកអាចរងចាំដល់អាយុលើស ១៨ ឆ្នាំទៀត នោះកាន់តែប្រសើរ។

(អ្នកសម្របសម្រួល គួររំឭកអ្នកចូលរួមពីអាយុស្របច្បាប់សម្រាប់ការធ្វើចំណាកស្រុកក្នុងប្រទេសរបស់គេ និងប្រាប់ថា អាយុស្របច្បាប់សម្រាប់ការធ្វើចំណាកស្រុកក្រៅប្រទេសគឺ ១៨ ឆ្នាំ)។

**នៅរៀនឲ្យបានច្រើន**

ប្រសិនបើអ្នកអាចនៅរៀនបានកាន់តែយូរ អ្នកនឹងទទួលបានការអប់រំកាន់តែច្រើន។ បែបនេះនឹង ជួយឲ្យអ្នកអាចដាក់សុំធ្វើការងារដែលល្អប្រសើរ ជាពិសេស ប្រសិនបើអ្នកបានរៀនជំនាញកុំព្យូទ័រ ឬភាសា ដូចជា ចិន ថៃ ឬ ភាសាអង់គ្លេសជាដើម។ វាក៏មានន័យថា អ្នកអាចយល់បានកាន់តែប្រសើរលើឯកសារនានាដូចជា កិច្ចសន្យាការងារជាដើម។

**រៀនសូត្រពីជំនាញវិជ្ជាជីវៈជាមុនសិន**

ដំបូងត្រូវរកមើលថា តើឧស្សាហកម្មណាខ្លះដែលកំពុងជួលបុគ្គលបម្រើការដែលអ្នកគិតថានឹងទៅ។ ប្រសិនបើជារោងចក្រកាត់ដេរ នោះត្រូវរៀនកាត់ដេរសិនមុនពេលអ្នកចេញទៅ។ ប្រសិនបើមានរោងចក្ររថយន្ត ចូលរៀនវគ្គគ្រឿងម៉ាស៊ីនឡានសិន។

**កំណត់ហេតុ**

ឲ្យអ្នកចូលរួមសរសេរ ឬគូររូបអំពីគ្រោះថ្នាក់ដែលអាចកើតមានដល់ជនចំណាកស្រុកដែលអាចនឹងជួបប្រទះប្រសិនបើគេមិនមានព័ត៌មាននៅលើតារាងត្រួតពិនិត្យ ៖ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព។

**ការបិទបញ្ចប់**

ប្រាប់ឲ្យអ្នកចូលរួមសរសេរ ឬសួរសំណួរ និង/ឬ ផ្តល់ជាព័ត៌មានត្រឡប់ និងប្រគល់ឲ្យទៅអ្នកសម្របសម្រួលដោយមិនបាច់បញ្ចូលឈ្មោះ។

អរគុណដល់អ្នកចូលរួមទាំងអស់គ្នាដែលបានមករៀន។ បញ្ជាក់ឡើងវិញអំពីការប្រជុំក្លិបពេលក្រោយ។ ប្រាប់ពួកគេថា ពួកគេទទួលបានផ្កាយមួយទៀតសម្រាប់ការចូលរួមក្នុងម៉ោងសិក្សានេះ។

ពន្យល់ថា ការធ្វើចំណាកស្រុកអាចជាការល្អ។ វាអាចឲ្យយុវវ័យរកការងារបានធ្វើ និងកសាងជីវិតបានល្អប្រសើរ។ តារាងត្រួតពិនិត្យនោះត្រូវបានបង្កើតឡើងដើម្បីជួយដល់អ្នកដែលចង់ធ្វើចំណាកស្រុកឲ្យមានសុវត្ថិភាពកាន់តែច្រើន ដូច្នេះគឺអាចទាញយកប្រយោជន៍ជាឱកាសដោយមិនមានការជួញដូរ ឬកេងប្រវ័ញ្ច។

ឆ្លើយសំណួរទាំងនេះ នៅពេលដែលអ្នកចាប់ផ្តើមការពិភាក្សាអំពីការផ្លាស់ទីកន្លែងដើម្បីរកការងារធ្វើ នៅខាងក្រៅសហគមន៍របស់អ្នក។ ពិភាក្សាសំណួរទាំងនេះជាមួយគ្រួសារអ្នក។

| **ព័ត៌មានអំពីគោលដៅរបស់អ្នក** | **បាទ/ចាស** | **ទេ** |
|---|---|---|
| តើអ្នកដឹងទេថា អ្នកនឹងទៅកន្លែងណា? ប្រសិនបើដឹង សរសេរឈ្មោះក្រុងនៅត្រង់កន្លែងនេះ ៖ ____________________ | | |
| តើអ្នកមានស្គាល់នរណាម្នាក់រស់នៅទីក្រុងដែលអ្នកនឹងទៅនោះដែរ ឬទេ? | | |
| តើអ្នកមានលេខទូរស័ព្ទរបស់ម្នាក់នោះដែរ ឬទេ? | | |
| តើអ្នកអាចទូរស័ព្ទទៅបុគ្គលនោះដើម្បីរៀបចំផែនការជួបគ្នាពេលអ្នកទៅដល់បានទេ? | | |
| **ព័ត៌មានអំពីការធ្វើដំណើរ** | **បាទ/ចាស** | **ទេ** |
| តើអ្នកដឹងពីវិធីធ្វើដំណើរត្រឡប់មកប្រទេសកំណើតវិញដែរឬទេនៅពេលដែលការងារត្រូវបានបញ្ចប់? | | |
| តើការធ្វើដំណើរត្រឡប់មកវិញត្រូវចំណាយអស់ប៉ុន្មាន?<br>សរសេរចំនួនទឹកប្រាក់នៅទីនេះ ៖ ____________________ | | |
| តើត្រូវចំណាយប៉ុន្មានដើម្បីរស់នៅបានក្នុងកន្លែងដែលអ្នកត្រូវទៅនោះ?<br>សរសេរចំនួនទឹកប្រាក់នៅទីនេះ ៖ ____________________ | | |
| តើអ្នកមានប្រាក់គ្រប់គ្រាន់សម្រាប់រស់នៅមួយរយៈនៅពេលអ្នកទើបទៅដល់ និងសម្រាប់ត្រឡប់មកផ្ទះវិញដែរ ឬទេ? | **បាទ/ចាស** | **ទេ** |
| *(ត្រូវចាំថា វាមានគ្រោះថ្នាក់ ប្រសិនបើអ្នកខ្ចីប្រាក់ពីអ្នកជ្រើសរើសឲ្យចូលធ្វើការ ឬពីថៅកែដើម្បីជាសោហ៊ុយធ្វើដំណើរ ឬប្រសិនបើអ្នកត្រូវជំពាក់ប្រាក់ដែលត្រូវបង់រំលោះទៅអ្នកជ្រើសរើសឲ្យចូលធ្វើការនោះ។ វាជាគ្រោះថ្នាក់មួយដែលទៅដល់កន្លែងធ្វើការថ្មីមួយដោយជំពាក់បំណុលអ្នកជ្រើសរើសឲ្យចូលធ្វើការ ឬថៅកែនោះ)។* | | |
| តើអ្នកនឹងធ្វើដំណើរទៅជាមួយមិត្តភក្តិមែនទេ? | | |
| **ព័ត៌មានអំពីការងារ** | **បាទ/ចាស** | **ទេ** |
| តើអ្នកមានស្គាល់នរណាម្នាក់ដែលត្រូវគេជ្រើសរើសឲ្យធ្វើការងារតាមរយៈបុគ្គលនេះ ឬជ្រើសរើសឲ្យចូលធ្វើការពីមុនដែរ ឬទេ? | | |
| តើអ្នកទទួលបានការងារធ្វើនិងធ្លាប់មកលេងផ្ទះម្តងម្កាលដែរ ឬទេ? | | |

| | | |
|---|---|---|
| តើអ្នកទទួលបានការងារធ្វើនិងធ្លាប់ទូរស័ព្ទមកលេងគ្រួសាររបស់គាត់ដែរ ឬទេ? | | |
| | បាទ/ចាស | ទេ |
| តើការងារនេះស្តាប់ទៅ ដូចគ្នានឹងការងារផ្សេងទៀតដែលអ្នកធ្លាប់បានឮដែរឬទេ? | | |
| តើការងារនេះផ្តល់កម្រៃស្មើគ្នានឹងការងារដែលអ្នកធ្លាប់ឮដែរ ឬទេ? (ប្រសិនបើវាស្តាប់ទៅល្អហួសពីការពិតនោះ វាប្រហែលជាការកុហក់)។ | | |
| តើមនុស្សដែលកំពុងរៀបចំការងារសម្រាប់អ្នកអាចប្រាប់អ្នកអំពីឈ្មោះរបស់ក្រុមហ៊ុនដែលអ្នកនឹងត្រូវទៅធ្វើការដែរ ឬទេ?<br>សូមសរសេរនៅទីនេះ ៖<br>______________________________ | | |
| តើបុគ្គលនោះអាចប្រាប់អ្នកពីអាសយដ្ឋាន និងលេខទូរស័ព្ទរបស់ក្រុមហ៊ុននោះបានដែរ ឬទេ? សូមសរសេរនៅទីនេះ ៖ ______________________ | | |
| តើអ្នកអាច រកមើលឈ្មោះ និងអាសយដ្ឋានរបស់ក្រុមហ៊ុននោះនៅតាមប្រព័ន្ធអិនធឺណិតបានដែរ ឬទេ? | | |
| តើអ្នកមានកិច្ចសន្យាដែរ ឬទេ? | | |
| ប្រសិនបើអ្នកមិនមានកិច្ចសន្យា តើអ្នកបានពិភាក្សាអំពីល័ក្ខខ័ណ្ឌនានាអំពីការងាររបស់អ្នកដែរ ឬទេ? | | |
| តើអ្នកអាចអាន និងយល់បានពីកិច្ចសន្យាទាំងមូលដែរ ឬទេ? | | |
| តើអ្នកព្រមព្រៀងជាមួយប្រការគ្រប់យ៉ាងដែលកិច្ចសន្យានោះចែងដែរ ឬទេ? | | |
| **ឯកសារ** | | |
| ប្រសិនបើអ្នកនឹងត្រូវទៅប្រទេសផ្សេងទៀតនោះ តើអ្នកមានលិខិតឆ្លងដែន និងទិដ្ឋាការការងារសម្រាប់ប្រទេសនោះដែរ ឬទេ? | | |
| **បុគ្គលដែលត្រូវទំនាក់ទំនង** | | |
| តើអ្នកនឹងនាំយកទៅជាមួយនូវទូរស័ព្ទចល័ត ដើម្បីអ្នកអាចទាក់ទងទៅកាន់គ្រួសាររបស់អ្នកបាននៅពេលដែលអ្នកទៅឆ្ងាយដែរ ឬទេ? | | |
| តើអ្នកស្គាល់អង្គការណាមួយ ឬបុគ្គលណាម្នាក់ដើម្បីទំនាក់ទំនងនៅក្នុងទីក្រុង/ប្រទេសផ្សេងដែរ ឬទេ ប្រសិនបើមានបញ្ហាអ្វីកើតឡើង ហើយអ្នកត្រូវការជំនួយ និងសុវត្ថិភាព? | | |
| តើមានប្រទេសផ្សេងទៀត - កិច្ចសន្យាជាក់លាក់ដែរ ឬទេ? | | |
| **អ្នកឆ្លើយ បាទ/ចាស បានកាន់តែច្រើន ផែនការរបស់អ្នកកាន់តែមានសុវត្ថិភាព។** | | |

# មេរៀនទី២៣ ៖ ការរក្សាសុវត្ថិភាព ពេលកំពុងធ្វើដំណើរ ២៣

**វត្ថុបំណង**

អ្នកចូលរួមនឹងសិក្សាអំពីយុទ្ធសាស្ត្រសម្រាប់ការរក្សាសុវត្ថិភាពពេលគេកំពុងធ្វើដំណើរចំណាកស្រុក

**សម្ភារៈ**

- កូនសៀវភៅនាវិកវៃឆ្លាត
- ឯកសារយោង “IS ២៣ក ៖ បញ្ជីត្រួតពិនិត្យ៖ ការធ្វើដំណើរដោយសុវត្ថិភាព” និង “IS ២៣ខ ៖ បញ្ជីត្រួតពិនិត្យ ៖ឯកសារសំខាន់ៗ”
- ស្លាកសញ្ញា“ឈប់”មួយយកពី“IS២៣គ៖ សញ្ញាឈប់”សម្រាប់អ្នកចូលរួមម្នាក់ៗ

**ពេលវេលា**

៧៥ នាទី

**សេចក្តីផ្តើម**

**ការស្វាគមន៍**

ស្វាគមន៍អ្នកចូលរួមដោយហៅឈ្មោះ។ ហុចបញ្ជីឈ្មោះតៗគ្នាដើម្បីចុះវត្តមាន។

**សកម្មភាពមុនចាប់ផ្តើម**

ឲ្យអ្នកសម្របសម្រួលជាយុវជនដឹកនាំល្បែងថាមពលក្នុងតារាង។

**ការរំឭកមេរៀន**

កាលពីប៉ុន្មានមេរៀនកន្លងទៅ យើងបានពិភាក្សាអំពី គំរូនៃការធ្វើសេចក្តីសម្រេចចិត្ត។ តើមានរណាអាចប្រាប់បានពីជំហានទាំង ៥ នៅក្នុងគំរូនៃការសម្រេចចិត្តដែរ ឬទេ? តើអ្នកនឹងប្រើប្រាស់ជំហានទាំងនេះនៅក្នុងជីវិតពិតរបស់អ្នកបានដែរ ឬទេ ?

## ការរក្សាសុវត្ថិភាពក្នុងពេលកំពុងធ្វើដំណើរ

ពន្យល់ថា ប្រសិនបើអ្នកចូលរួមបានអនុវត្តតាមគ្រប់ជំហានទាំងអស់ ហើយបានធ្វើសេចក្តីសម្រេច ចិត្តដើម្បីធ្វើចំណាកស្រុក ពេលនេះគេចាំបាច់ត្រូវដឹងពីវិធីធ្វើដំណើរប្រកបដោយសុវត្ថិភាព។

ប្រាប់អ្នកចូលរួមថា មុនពេលគេធ្វើចំណាកស្រុក គេគួរបំពេញ “តារាងត្រួតពិនិត្យ ៖ការធ្វើចំណាកស្រុកដោយសុវត្ថិភាព” ដែលត្រូវបានពិភាក្សាកាលពីមេរៀនមុននេះ។

បន្ទាប់មក គេត្រូវកំណត់ទីតាំង និងរៀបចំឯកសារសំខាន់ៗរបស់គេ។ ឲ្យអ្នកចូលរួមបើកទៅទំព័រនិយាយអំពី “តារាងត្រួតពិនិត្យ ៖ ឯកសារសំខាន់ៗ” នៅក្នុងកូនសៀវភៅនាវិកវៃឆ្លាត (រួមទាំង “IS ២៣ខ ៖ “តារាងត្រួតពិនិត្យ ៖ ឯកសារសំខាន់ៗ” នៅខាងក្រោម នេះផងដែរ)។

ពន្យល់ថា ខាងក្រោមនេះគឺជា ឯកសារមួយដែលគេត្រូវការដើម្បីធ្វើចំណាកស្រុក។ សួរថា តើមាននរណានៅចាំទេថា អ្វីជាលិខិតឆ្លងដែន និងអ្វីជាទិដ្ឋាការ។

រំឭកអ្នកចូលរួមថា លិខិតឆ្លងដែន គឺជាឯកសារដែលចេញដោយប្រទេសដើមរបស់គេដែលគេត្រូវតែ បង្ហាញនៅពេលដែលគេឆ្លងកាត់ព្រំដែនអន្តរជាតិ។ នៅពេលដែលគេមានលិខិតឆ្លងដែន

ពីប្រទេសរបស់គេ គេអាចដាក់ពាក្យស្នើសុំទិដ្ឋាការដើម្បីចូលទៅក្នុងប្រទេសផ្សេងទៀតបាន។ រំឭកអ្នកចូលរួមថា ការរក្សាលិខិតឆ្លងដែនរបស់គេឲ្យមានសុវត្ថិភាពគឺជាអាទិភាពចម្បងនៅពេលដែលគេធ្វើដំណើរ ឬធ្វើចំណាកស្រុក។ ត្រូវរំឭកអ្នកចូលរួមថា មិនត្រូវឲ្យវាទៅនរណាម្នាក់ឡើយដើម្បី "រក្សាសុវត្ថិភាព"។

រំឭកអ្នកចូលរួមថា ទិដ្ឋាការ គឺជាត្រា ឬស្ទីគ័រដែលមាននៅក្នុងលិខិតឆ្លងដែនរបស់គេ ពីប្រទេសដើមរបស់គេដែលអនុញ្ញាតិឲ្យគេចូលទៅក្នុងប្រទេសនោះបាន។ រំឭកអ្នកចូលរួមថា ប្រទេសដែលគេចង់ទៅនោះ អាចនឹងមិនផ្ដល់ទិដ្ឋាការឲ្យទេ។

ពន្យល់ថា មានទិដ្ឋាការប្រភេទផ្សេងៗគ្នា។ ទិដ្ឋាការការងារអនុញ្ញាតិឲ្យអ្នកធ្វើការងារដោយស្របច្បាប់នៅក្នុងប្រទេសមួយ៖ ទិដ្ឋការទេសចរណ៍ មានន័យថា គេអាចដើរទេស្សនាបាន ប៉ុន្តែមិនអាចធ្វើការដោយស្របច្បាប់បានទេ។

កត់ចំណាំថា បើទោះបីជាគេមិនមានឯកសារគ្រប់ដូចមានក្នុង តារាងត្រួតពិនិត្យក៏ដោយ គ្រាន់តែថា បើគេមានឯកសារកាន់តែច្រើន គឺគេកាន់តែមានសុវត្ថិភាព។

ពន្យល់ថា ពួកគេគួរតែមានការប្រុងប្រយ័ត្នជាមុនដើម្បីឲ្យប្រាដកថា ឯកសាររបស់គេមានសុវត្ថិភាព ក្នុងពេលកំពុងធ្វើដំណើរ។ អានឲ្យឮៗនូវការប្រុងប្រយ័ត្នជាមុនចំនួនពីរចំណុចដែលគេអាចអនុវត្តបាន ៖

១. ដំបូងគឺត្រូវ ថតចម្លងឯកសារជាពីរច្បាប់ នូវលិខិតឆ្លងដែន ទិដ្ឋាការ កិច្ចសន្យាការងារ និងអត្តសញ្ញាណប័ណ្ណ (ប្រសិនបើអ្នកមានឯកសារទាំងនេះ) ។

អ្នកគួរទុកច្បាប់ថតចម្លងនៃឯកសាររបស់អ្នកនៅគ្រួសារ ឬមិត្តភក្តិរបស់អ្នកនៅក្នុងផ្ទះរបស់អ្នក ហើយយកមួយច្បាប់ទៀតតាមខ្លួនអ្នក។ មិនត្រូវទុកឯកសារថតចម្លងនៅក្នុងកន្លែងជាមួយគ្នានឹងឯកសារច្បាប់ដើមឡើយ។

ប្រសិនបើឯកសាររបស់អ្នកបាត់ ឬត្រូវគេលួចនោះពេលកំពុងធ្វើដំណើរនោះ ឯកសារថតចម្លងនឹងអាចប្រើជំនួសវិញបានយ៉ាងងាយ។

ប្រសិនបើក្រុមគ្រួសាររបស់អ្នកបាត់ដំណឹងអ្នក ហើយមានការបារម្ភពីអ្នក ឯកសារថតចម្លងក៏នឹងផ្ដល់ភាពងាយស្រួលសម្រាប់គេដើម្បីរាយការណ៍អំពីការបាត់ខ្លួនអ្នកទៅកាន់អាជ្ញាធរនានាផងដែរ ហើយអាចរកអ្នកឃើញវិញ។

២. ការមានភាពប្រុងប្រយ័ត្នមុន គឺត្រូវរកកន្លែងល្អ ដើម្បីលាក់ទុកឯកសាររបស់អ្នកនៅក្នុងខោអាវរបស់អ្នក (មិនមែននៅក្នុងកាតាបទេ) ពេលអ្នកកំពុងធ្វើដំណើរ។ ជនចម្លែកនឹងមិនអាចឃើញកន្លែងដែលអ្នកទុកឯកសារនោះទេ។

ឲ្យអ្នកចូលរួមមើល "តារាងត្រួតពិនិត្យ ៖ ការធ្វើដំណើរដោយសុវត្ថិភាព" នៅក្នុងកូនសៀវភៅនាវិកវៃឆ្លាតរបស់គេ (រួមទាំង "IS ២៣ខ ៖ "តារាងត្រួតពិនិត្យ ៖ ឯកសារសំខាន់ៗ" នៅខាងក្រោមនេះផងដែរ)។ ឲ្យអ្នកចូលរួមអានតារាងនេះឲ្យឮៗ។ សួរថា

- តើអ្នកគិតថា ការប្រុងប្រយ័ត្នមុនបែបនេះអាចជួយឲ្យអ្នកធ្វើដំណើរកាន់តែមានសុវត្ថិភាពដែរ ឬទេ?
- តើមានឧបសគ្គអ្វីខ្លះដែលអាចកើតមានចំពោះការប្រុងប្រយ័ត្នមុននេះ?
- តើយើងអាចជម្នះឧបស័គ្គទាំងនេះបានដោយរបៀបណា?

## ការលេងរឿងឈប់

ចែកស្លាកសញ្ញា "ឈប់" (IS ២៣គ៖ សញ្ញា "ឈប់")។ ពន្យល់ថា អ្នកនឹងអានរឿងអំពីការធ្វើចំណាកស្រុក។គ្រប់ពេលវេលាទាំងអស់ គឺជនចំណាកស្រុកធ្វើអ្វីក៏ប្រកបដោយគ្រោះថ្នាក់ដែរ អ្នកចូលរួមគួរលើកសញ្ញា "ឈប់" ឡើង ហើយនិយាយថា "ឈប់"។ បន្ទាប់មកអ្នកចូលរួមត្រូវពន្យល់ថា គ្រោះថ្នាក់ជាអ្វី ហើយជនចំណាកស្រុកគួរធ្វើអ្វីខ្លះ។ អានរឿងខាងក្រោមឲ្យ ឮៗ ៖

ស គឺជាស្ត្រីវ័យក្មេងម្នាក់ដែលរៀនសូត្រមិនបានច្រើន ហើយបានសម្រេចចិត្តធ្វើចំណាកស្រុក។ (**ឈប់** - នាងគួរតែរៀនបន្តទៀតប្រសិនបើអាច) ។ នាងបានចាប់ផ្តើមគិតពីកន្លែងដែល នាងអាច ធ្វើដំណើរទៅដើម្បីរកការងារធ្វើ។

នាងបានជួបបុរសម្នាក់ដែលបុរសនោះបានប្រាប់នាងថា គេអាចរកការងារមួយឲ្យនាងធ្វើបាន ដែលទទួលបានប្រាក់ខែចំនួន ២០០ ដុល្លារ។ នាងបានពិភាក្សាអំពីការសម្រេចចិត្តជាមួយនឹង គ្រួសាររបស់នាង។ ក្រោយមក នាងបានសម្រេចចិត្តខ្ចីប្រាក់អ្នកចងការប្រាក់ម្នាក់នៅក្នុងសហគមន៍ របស់នាងដោយដាក់បញ្ចាំស្រែរបស់គ្រួសារនាង (**ឈប់** - នាងមិនគួរព្យាយាមជំពាក់បំណុលគេដើម្បីការធ្វើចំណាកស្រុក ហើយទុកឲ្យទ្រព្យសម្បត្តិគ្រួសាររបស់នាងស្ថិតក្នុងគ្រោះថ្នាក់បែបនេះទេ)។

នាងបានឲ្យប្រាក់ ២០០ ដុល្លារទៅឈ្មួញកណ្តាលនោះ ហើយបានចុះកិច្ចសន្យាជាភាសាដែលនាងមិនអាចអានបាន។ (**ឈប់** - នាងមិនគួរចុះកិច្ចសន្យាដែលនាងមិនអាចអានបានបែបនេះទេ)។

ស មានអត្តសញ្ញាណប័ណ្ណ។ ឈ្មួញកណ្តាលបានយកអត្តសញ្ញាណប័ណ្ណនោះពីនាង ដោយនិយាយថា គេត្រូវការទុកវាសម្រាប់ថៅកែរបស់នាង។ (**ឈប់** - នាងមិនគួរឲ្យអត្តសញ្ញាណប័ណ្ណ របស់ខ្លួនទៅឲ្យអ្នកដទៃទេ)។

នាងមិនបានថតចម្លងទុកឯកសារចម្លងណាមួយទុកនៅគ្រួសាររបស់នាងទេ។ (**ឈប់** - នាងគួរទុកឯកសារថតចម្លងមួយច្បាប់នៅគ្រួសាររបស់នាង)។

ស មានមិត្តភក្តិម្នាក់ដែលបានធ្វើចំណាកស្រុកនៅក្នុងប្រទេសរបស់ខ្លួន។ ប៉ុន្តែឈ្មួញ កណ្តាលនោះបានប្រាប់នាងថា គេត្រូវទៅកន្លែងមួយនៅប្រទេសថៃជាទីដែលនាងមិនធ្លាប់ស្គាល់។ (**ឈប់** - នាងគួរតែដឹងពីកន្លែងដែលនាងត្រូវទៅ និងឈ្មោះថៃកែរបស់នាងផងដែរ។ ប្រសិនបើអាចគឺនៅមុនពេលនាងចាកចេញទៅ)។

ស មកពីគ្រួសារក្រីក្រមួយ។ ពេលដែលនាងចាកចេញពីភូមិរបស់នាង នាងស្ទើរតែគ្មានប្រាក់ជាប់ហោប៉ៅ។ (**ឈប់** - នាងគួរតែមានប្រាក់គ្រប់គ្រាន់ដើម្បីរស់នៅមួយរយៈពេលនាងទៅដល់ភ្លាមៗ និងចំណាយសម្រាប់សំបុត្រត្រឡប់មកផ្ទះវិញ ប្រសិនបើនាងមិនអាចរកការងារបាននៅពេលនាងទៅដល់)។

នាងមិនមានទូរស័ព្ទដៃ ហើយមិនស្គាល់លេខទូរស័ព្ទរបស់នរណាម្នាក់នៅក្នុងភូមិរបស់នាងទេ។ (**ឈប់** - នាងគួរតែព្យាយាមកាន់ទូរស័ព្ទជាប់ដៃ ឬយ៉ាងហោចក៏គួតែស្គាល់លេខទូរស័ព្ទដៃរបស់ នរណាម្នាក់ នៅក្នុងភូមិរបស់នាងដែរមុនពេលនាងចាកចេញទៅ)។

ដំបូង ស សន្មតថា នាងនឹងទៅធ្វើការនៅប្រទេសផ្សេងដោយស្របច្បាប់។ ប៉ន្តែក្រោយមកឈ្មួញនោះបានប្រាប់នាងថា គេត្រូវចាកចេញពេលយប់ពីព្រោះគេនឹងត្រូវធ្វើដំណើរឆ្លងកាត់

ព្រំដែនចូលប្រទេសថៃដោយខុសច្បាប់។ (**ឈប់**-នាងគួរតែធ្វើចំណាកស្រុកដោយស្របច្បាប់ប្រសិនបើអាច)។

បន្ទាប់ពីបានធ្វើដំណើរឆ្លងកាត់ព្រំដែនដោយខុសច្បាប់ហើយ ស ជិះរថយន្តឯកជនមួយ (**ឈប់** - នាងមិនគួរជិះរថយន្តឯកជនបែបនេះទេ)

## សំណួរវាស់ស្ទង់ចំណេះដឹង

លេងល្បែងបាល់ចង់ចាំ ពីសកម្មភាពមុនចាប់ផ្តើមនៅពេលផ្នែកខាងដើមនៃឯកសារកម្រងនេះ ទំព័រទី១០។

## ការសម្តែងរឿង

ឲ្យអ្នកចូលរួមបែងចែកជាក្រុមដែលមានគ្នាពី ៨-១២ នាក់។ ឲ្យក្រុមនីមួយៗរៀបចំត្រៀមការសម្តែងរឿងដោយផ្អែកលើសេណារីយ៉ូនេះ ៖

ជនចំណាកស្រុកម្នាក់ធ្វើដំណើរតាមរថយន្តក្រុងមួយ។ ដំបូង អ្នកធ្វើដំណើរជាមួយមួយចំនួនព្យាយាម ផ្តល់ការងារឲ្យជនចំណាកស្រុកម្នាក់នោះ។ ជនចំណាកស្រុកម្នាក់នោះប្រើជំនាញទំនាក់ទំនងបែបម៉ឺងម៉ាត់ដើម្បីបដិសេធន៍។ បន្ទាប់មកអ្នកបើកបរថយន្តក្រុងនោះព្យាយាមបញ្ចុះបញ្ចូលឲ្យជនចំណាកស្រុកនោះ ចុះទៅជិះរថយន្តឯកជនមួយទៀត នៅចំណតបន្ទាប់។ តើជនចំណាកស្រុកម្នាក់នោះត្រូវធ្វើអ្វី?

### សង្ខេបមេរៀន

- បំពេញ តារាងត្រួតពិនិត្យអំពី "ការធ្វើដំណើរដោយសុវត្ថិភាព" និង "ឯកសារសំខាន់ៗ"នៅក្នុងកូនសៀវភៅរបស់អ្នក មុនពេលអ្នកចាកចេញ។
- ទុកច្បាប់ថតចម្លងមួយច្បាប់ នៃឯកសារសំខាន់ៗរបស់អ្នក នៅជាមួយនរណាម្នាក់ ដែលអ្នកជឿទុកចិត្តនិងយកតាមខ្លួននូវឯកសារថតចម្លង ដោយដាក់វាដាច់ដោយឡែកពីឯកសារច្បាប់ដើម។ លាក់ទុកឯកសារច្បាប់ដើមរបស់អ្នកក្នុងកន្លែងណាដែលគេមើលមិនឃើញ។
- យកតាមខ្លួននូវកូនសៀវភៅនារីកវៃឆ្លាត។
- ធ្វើដំណើរដោយមានប្រាក់គ្រាប់គ្រាន់សម្រាប់ការរស់នៅមួយរយៈពេលគ្មានការងារធ្វើ និងទុកចំណាយសម្រាប់ការធ្វើដំណើរត្រឡប់មកផ្ទះវិញ។
- មិនត្រូវឲ្យឯកសាររបស់អ្នកទៅអ្នកដទៃឡើយ។
- ត្រូវមានការសង្ស័យលើជនចម្លែក ឬ "មិត្តភក្តិក្លែងក្លាយ" ពីព្រោះគេអាចជាអ្នកជួញដូរមនុស្ស។

## ការបិទបញ្ចប់

ប្រាប់ឲ្យអ្នកចូលរួមសរសេរ ឬសួរសំណួរ និង/ឬ ផ្តល់ជាព័ត៌មានត្រឡប់ និងប្រគល់ឲ្យទៅអ្នកសម្របសម្រួលដោយមិនបាច់បញ្ចេញឈ្មោះ។

អរគុណដល់អ្នកចូលរួមទាំងអស់គ្នា ដែលបានមករៀន។ បញ្ជាក់ឡើងវិញអំពីការប្រជុំគ្លីបពេលក្រោយ។ ប្រាប់ពួកគេថាពួកគេទទួលបានផ្កាយមួយទៀតសម្រាប់ការចូលរួមក្នុងម៉ោងសិក្សានេះ។ ឲ្យអ្នកចូលរួម សួរយោបល់ពីឪពុកម្តាយរបស់គេអំពីរបៀបធ្វើយ៉ាងណាដើម្បីធ្វើដំណើរ ប្រកបដោយសុវត្ថិភាព។ អ្នកសម្របសម្រួលឲ្យអ្នកចូលរួមកត់ត្រាទុកសំណួរនេះក្នុងក្រដាសដើម្បីយកទៅផ្ទះកុំឲ្យភ្លេច។

# IS ២៣ក ៖ តារាងត្រួតពិនិត្យ ការធ្វើដំណើរដោយសុវត្ថិភាព ២៣

## ពិនិត្យមើលថា តើអ្នកបានបំពេញសំណួរណាខ្លះ ✓

| | |
|---|---|
| រិះរកជម្រើសសម្រាប់ធ្វើចំណាកស្រុកមានឯកសារស្របច្បាប់។ វាមានសុវត្ថិភាពជាង។ | |
| បំពេញតារាងត្រួតពិនិត្យអំពី"ការធ្វើដំណើរដោយសុវត្ថិភាព"និង"ឯកសារសំខាន់ៗ" នៅក្នុងកូនសៀវភៅរបស់អ្នក មុនពេលអ្នកចាកចេញ។ | |
| ចំណាំទុកលេខទូរស័ព្ទសម្រាប់ហៅមកផ្ទះពីប្រទេសថ្មីនោះ មុនពេលអ្នកចាក់ចេញ (មើល"IS ២៤គ៖ របៀបទូរស័ព្ទមកផ្ទះ")។ | |
| ទុកច្បាប់ថតចម្លងមួយច្បាប់ នៃឯកសារសំខាន់ៗរបស់អ្នក នៅជាមួយនរណាម្នាក់ដែលអ្នកជឿទុកចិត្ត (ប្រសិនបើមានបញ្ហា ឬបាត់បង់ឯកសាររបស់អ្នកវានឹងជួយដល់គ្រួសាររបស់អ្នកក្នុងការជួយអ្នក) | |
| យកឯកសារថតចម្លងតាមខ្លួន ដោយដាក់វាដាច់ដោយឡែកពីឯកសារច្បាប់ដើម។ | |
| ធ្វើដំណើរដោយមានប្រាក់គ្រាប់គ្រាន់សម្រាប់ការរស់នៅមួយរយៈពេលគ្មានការងារធ្វើនិងទុកសម្រាប់ត្រឡប់មកផ្ទះវិញ។ | |
| រក្សាទុក កូនសៀវភៅនាវិកវៃឆ្លាត ឯកសាររបស់អ្នក និងប្រាក់នៅក្នុងកន្លែងលាក់ជិតមានសុវត្ថិភាពក្នុងសម្លៀកបំពាក់របស់អ្នក។ | |

**ចំណាំ ៖**

- ធ្វើដំណើរជាក្រុមជាមួយនឹងអ្នកចំណាកស្រុកផ្សេងទៀតដូចអ្នកដែរ (វាពិបាកក្នុងការបោកប្រាស់មនុស្សច្រើននាក់ក្នុងពេលតែមួយ ហើយជាក្រុមមានន័យថា អ្នកមានមិត្តដើម្បីជួយគ្នាបាន)។
- ត្រូវមានការសង្ស័យលើជនចម្លែក នៅក្នុងការធ្វើដំណើរចំណាកស្រុករបស់អ្នក (គេអាចជាអ្នកជួញដូរមនុស្ស)។
- ប្រសិនបើមាននរណាបង្ខំអ្នកឲ្យប្រគល់ឯកសារឲ្យគេសុំឲ្យអ្នកដំណើរផ្សេងទៀត ឬមន្ត្រីឲ្យជួយអ្នក។
- មិនត្រូវទៅតាមមនុស្សចម្លែកនៅតាមរថភ្លើង ឬរថយន្តក្រុងឡើយ។
- ព្យាយាមជៀសវាងការជិះរថយន្តឯកជន ឬ រថយន្តដឹកអ្នកដំណើរខ្នាតតូច។

# ២៣ IS ២៣ខ ÷ តារាងត្រួតពិនិត្យ ÷ ឯកសារសំខាន់ៗ



ខាងក្រោមនេះគឺជាតារាងបញ្ជីលេខ និងឯកសារដែលអ្នកគួរតែយកតាមខ្លួនអ្នកនៅពេលដែលអ្នកធ្វើចំណាកស្រុក។ **ត្រូវថតចម្លងឯកសារទុកពីរច្បាប់។** ទុកមួយច្បាប់នៅផ្ទះ និងមួយច្បាប់ទៀតយកតាមខ្លួន។ ទុកច្បាប់ថតចម្លងរបស់អ្នកនៅដាច់ដោយឡែកពីច្បាប់ដើម ដូច្នេះបើច្បាប់ដើមបាត់ ឬត្រូវគេលួចយក អ្នកមានច្បាប់ថតចម្លងដើម្បីបង្ហាញអាជ្ញាធរ។

**សរសេរលេខទូរស័ព្ទ និងអាសយដ្ឋានខាងក្រោមប្រសិនបើអ្នកមាន៖**

- លេខទូរស័ព្ទគ្រួសាររបស់អ្នកផ្ទាល់ ៖ ______________________

- លេខទូរស័ព្ទអ្នកដែលកំពុងធ្វើការងារនៅទីនោះ: ______________________

- លេខទូរស័ព្ទមនុស្សដែលអ្នកស្គាល់រស់នៅក្នុងតំបន់គោលដៅរបស់អ្នក

  ______________________

- លេខទូរស័ព្ទសង្គ្រោះបន្ទាន់/អង្គការ NGO នៅកន្លែងដែលអ្នកធ្វើដំណើរទៅក្នុងករណីអ្នកត្រូវការជំនួយ ______________________

- លេខទូរស័ព្ទប៉ូលីស ______________________

- ឈ្មោះ និងអាសយដ្ឋានកន្លែងដែលអ្នកនឹងទៅធ្វើការ។

  ______________________

  ______________________

- ឈ្មោះ និងអាសយដ្ឋានស្ថានទូតប្រទេសរបស់អ្នក នៅក្នុងប្រទេសគោលដៅ។

  ______________________

  ______________________

- ឈ្មោះ និងអាសយដ្ឋានរបស់អង្គការ NGO មួយដូចជាអង្គការទស្សនៈពិភពលោកជាដើម នៅក្នុងប្រទេសគោលដៅ

  ______________________

  ______________________

| តារាងត្រួតពិនិត្យ ៖ តើអ្នកមាន ? | បាទ/ចាស | ទេ |
|---|---|---|
| លិខិតឆ្លងដែន (បើធ្វើដំណើរទៅប្រទេសដទៃ)។ | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |


STOP

# មេរៀនទី២៤ ÷ នៅពេលអ្នកទៅដល់ ២៤

## វត្ថុបំណង

អ្នកចូលរួមនឹងរៀនពីយុទ្ធសាស្ត្រ ដើម្បីស្នាក់នៅសុវត្ថិភាព នៅពេលគេចំណាកស្រុកទៅដល់កន្លែងគោលដៅ។

## សម្ភារៈ :

- ឯកសារយោង "IS ២៤ក ៖ សុវត្ថិភាពពេលអ្នកទៅដល់"
- ថតចម្លង"IS២៤ខ៖រូបថ្លុកអំពីដំណាក់កាលនៃការធ្វើចំណាកស្រុក"(គ្រប់គ្រាន់សម្រាប់ចំនួនសិស្សពាក់កណ្តាលនៅក្នុងក្រុម យុវជននឹងប្រើរូបថ្លុកនោះជាគូ)
- ឯកសារយោង "IS ២៤គ ៖ របៀបហៅទូរស័ព្ទមកផ្ទះ"
- កូនសៀវភៅនាវិកវៃឆ្លាត

## ពេលវេលា

៧៥ នាទី

## សេចក្តីផ្តើម

### ការស្វាគមន៍

ស្វាគមន៍អ្នកចូលរួមដោយហៅឈ្មោះ។

ហុចតៗគ្នានូវបញ្ជីចុះហត្ថលេខាវត្តមាន។

### សកម្មភាពមុនចាប់ផ្តើម

ឲ្យអ្នកសម្របសម្រួលជាយុវជនដឹកនាំល្បែងថាមពលនៅក្នុងតារាង។

### ការរំឭកមេរៀន

តើមានវណាអាចប្រាប់បានពីយុទ្ធសាស្ត្រខ្លះ ដែលអ្នកអាចប្រើប្រាស់ ដើម្បីរក្សាសុត្ថិភាពក្នុងពេលកំពុងធ្វើដំណើរបានដែរឬទេ?

តើឪពុកម្តាយរបស់អ្នកបានផ្តល់នូវដំបូន្មានខ្លះៗ អំពីរបៀបធ្វើដំណើរ ប្រកបដោយសុវត្ថិភាពដែលឬទេ?

តើអ្នកមានភាពជឿជាក់ក្នុងការប្រើយុទ្ធសាស្ត្រទាំងនេះដែរឬទេ?

បើមានហេតុអ្វី? បើមិនមានហេតុអ្វី?

## សុវត្ថិភាពពេលអ្នកទៅដល់

ចែកកូនសៀវភៅនាវិកវៃឆ្លាត។ ឲ្យអ្នកចូលរួមបើកទៅទំព័រនិយាយអំពី "តារាងត្រួតពិនិត្យ ៖ សុវត្ថិភាពពេលអ្នកទៅដល់" នៅក្នុងកូនសៀវភៅនាវិកវៃឆ្លាតរបស់គេ (រួមទាំង"IS២៤ក៖សុវត្ថិភាពពេលអ្នកទៅដល់" នៅខាងក្រោមនេះផងដែរ)។

ឲ្យអ្នកចូលរួមអានពីវិធីស្នាក់នៅដោយសុវត្ថិភាពនៅក្នុងតារាង។

ឥឡូវនេះ ឲ្យអ្នកចូលរួមបើកទៅទំព័រនិយាយអំពី "របៀបហៅទូរស័ព្ទមកផ្ទះ" (រួមទាំង"IS២៤គ៖របៀបហៅទូរស័ព្ទមកផ្ទះ" នៅខាងក្រោមនេះផងដែរ)។ ឲ្យអ្នកចូលរួមអានការណែនាំ។

សួរទៅក្រុមថា ៖

- តើអ្នកយល់ពីការណែនាំទាំងនេះដែររឺទេ?
- តើអ្នកអាចប្រើប្រាស់វាបានដែរឬទេ? ហេតុអ្វីបាន ឬ ហេតុអ្វីមិនបាន?
- តើអ្នកអាចគិតពីមធ្យោបាយផ្សេងទៀតដែល អ្នកចូលរួមអាចនៅមានសុវត្ថិភាបនៅពេលដែលគេទៅកន្លែងការងារថ្មី? តើអ្នកអាចចែករំលែកមធ្យោបាយនោះជាមួយក្រុមបានដែរ ឬទេ?

## រូបថ្លុកនិយាយអំពីដំណាក់កាលនៃការធ្វើចំណាកស្រុក

ចែក "TS ២៤ខ ៖ រូបថ្លុកនិយាយអំពីដំណាក់កាលនៃការធ្វើចំណាកស្រុក"។ ពន្យល់អ្នកចូលរួមថា រូបភាពទាំងនេះ ប្រាប់អំពីរឿង នៃការធ្វើដំណើររបស់យុវជនម្នាក់ ទៅកាន់ទីក្រុងធំមួយដើម្បីរកការងារធ្វើ។ ឲ្យអ្នកចូលរួមបែងចែក ក្រុមដែលមានគ្នាពីរ ឬបីនាក់។ បន្ទាប់មក អានរឿងបន្ទាប់ មកសរសេរ ពពុះគំនិតដែលនាងអាចធ្វើបាននៅក្នុង ដំណាក់កាលនីមួយៗដើម្បីបង្កើនសុវត្ថិភាពរបស់នាង។

## សំណួរខាស់ស្ទង់ចំណេះដឹង

លេងល្បែងបាល់ចង់ចាំ ពីសកម្មភាពល្បែងថាមពលនៅក្នុងសៀវភៅឧបករណ៍នេះ។

## កំណត់ហេតុ

ឲ្យអ្នកចូលរួមសរសេរ ឬគូររូបនៅក្នុងសៀវភៅកំណត់ហេតុរបស់គេ។

### សង្ខេបមេរៀន

- ទូរស័ព្ទមកគ្រួសាររបស់អ្នកឲ្យបានញឹកញាប់ និងប្រាប់ពួកគេអំពីព័ត៌មានលំអិតអំពីការរស់នៅរបស់អ្នក។
- ទៅមើលកន្លែង ដែលអ្នកនឹងត្រូវទៅធ្វើការងារ។ ធ្វើការសម្រេចចិត្ត ប្រសិនបើលក្ខខណ្ឌការងារ មិនមានបញ្ហា។
- បង្កើតបណ្តាញជាមួយមិត្តភក្តិផ្សេងៗដែលកំពុងស្ថិតក្នុងស្ថានភាពដូចអ្នក។ ប៉ុន្តែត្រូវចាំថា មនុស្សជាច្រើនត្រូវបានគេជួញដូរដោយមនុស្សដែលគេស្គាល់។
- សិក្សាពីទីតាំងស្ថានីយ៍ប៉ូលីស ស្ថានីយ៍រថយន្តក្រុង និងអង្គការ NGO ក្នុងមូលដ្ឋាន ឬមជ្ឈមណ្ឌល គាំទ្រជនអន្តោប្រវេសន៍នានា។
- មិនត្រូវផ្ញើប្រាក់ទៅផ្ទះតាមស្រោមសំបុត្រនោះទេ ពីព្រោះវាអាចនឹងត្រូវគេលួចយក។

## ការបិទបញ្ចប់

ប្រាប់ឲ្យអ្នកចូលរួមសរសេរ ឬសួរសំណួរ ផ្តល់ជាព័ត៌មានត្រឡប់ និងប្រគល់ឲ្យទៅអ្នកសម្របសម្រួលដោយមិនបាច់បញ្ចេញឈ្មោះ។

អរគុណដល់អ្នកចូលរួមទាំងអស់គ្នា ដែលបានចូលរួម។ បញ្ជាក់ឡើងវិញអំពីការប្រជុំក្លិបពេលក្រោយ។ ប្រាប់ពួកគេថា ពួកគេទទួលបានផ្កាយមួយទៀតសម្រាប់ការចូលរួមក្នុងមេរៀននេះ។

ឲ្យអ្នកចូលរួមសួរទៅឪពុកម្តាយ អ្នកផ្តល់ការថែទាំ ឬមិត្តភក្តិរបស់គេ នៅក្នុងសហគមន៍នូវសំណួរខាងក្រោម ៖

- តើអ្នកមានយោបល់យ៉ាងណាដែរអំពីរបៀបដែលមនុស្សម្នាក់អាចស្នាក់នៅដោយសុវត្ថិភាពបន្ទាប់ពីការធ្វើចំណាកស្រុក?
- តើអ្នកមានស្គាល់នរណាដែលធ្លាប់ធ្វើចំណាកស្រុកដែរ ឬទេ?
- តើគេរក្សាទំនាក់ទំនងមកផ្ទះរបស់គេដែរ ឬទេ?

អ្នកសម្របសម្រួលឲ្យអ្នកចូលរួមកត់ត្រាទុកសំណួរនេះក្នុងក្រដាសដើម្បីយកទៅផ្ទះកុំឲ្យភ្លេច។ ប្រាប់គេសថា សប្តាហ៍ក្រោយ យើងនឹងជជែកអំពីប្រធានបទមួយដែលពិបាកគឺតើអ្នកត្រូវធ្វើដូចម្តេចប្រសិនបើអ្នកត្រូវបានគេជួញដូរនោះ។

| | ✓ |
|---|---|
| **អ្វីដែលអ្នកគួរធ្វើនៅពេលទៅដល់គោលដៅ** | **ពិនិត្យនៅពេលដែលអ្នកបានធ្វើរួច** |
| នៅពេលដែលអ្នកទៅដល់ភ្លាម សួរគេពីឈ្មោះទីក្រុង និងអ្នកជិតខាងដែលអ្នកនៅក្បែរ។ សិក្សាពីរបៀបពន្យល់ប្រាប់គេអំពីទីកន្លែងដែលអ្នករស់នៅ។ (ការធ្វើបែបនេះនឹងជួយអ្នកនៅពេលដែលអ្នកមានបញ្ហាអ្វី) ។ | |
| ទូរស័ព្ទ ទៅគ្រួសាររបស់អ្នកភ្លាម នៅពេលដែលអ្នកទៅដល់ (កូនសៀវភៅនាវិកវៃឆ្លាត របស់អ្នកមានព្យល់ពីរបៀបហៅទូរស័ព្ទទៅផ្ទះ)។ ប្រាប់គេអំពីទីតាំងដែល អ្នករស់នៅ ហើយ ប្រសិនបើ អាចឲ្យលេខទូរស័ព្ទ មិត្តភក្តិ អ្នកដែលគេអាចទូរស័ព្ទមករកអ្នកបាន។ | |
| ទូរស័ព្ទទៅឪពុកម្តាយរបស់អ្នកជាទៀងទាត់។ វាជាការល្អដែលអ្នកត្រូវរៀបចំផែនការជាមួយឪពុកម្តាយរបស់អ្នកដើម្បីទូរស័ព្ទ ទៅពួកគាត់ក្នុងមួយសប្តាហ៍នៅថ្ងៃនិងម៉ោងដដែល។ ការធ្វើបែបនេះគឺមានន័យថា ប្រសិនបើអ្នកបាត់ខ្លួន និង មិនបានទូរស័ព្ទទៅ ពួកគាត់ នោះគាត់នឹងដឹងថា អ្នកកំពុងមានបញ្ហាហើយ។ ប្រាប់ ពួក គាត់ប្រសិនបើអ្នកមានបញ្ហា។ និយាយជាមួយឪពុកម្តាយរបស់អ្នកអំពីបញ្ហារបស់អ្នក។ | |
| ទៅមើលឲ្យដល់កន្លែងដែលអ្នកនឹងត្រូវទៅធ្វើការងារ។ ធ្វើការសម្រេចចិត្តលក្ខខ័ណ្ឌការងារមិនមានបញ្ហា។ | |
| រក្សាទំនាក់ទំនងជាមួយជនចំណាកស្រុកដែលធ្វើដំណើរជាមួយគ្នា។ បង្កើតបណ្តាញមិត្តភក្តិផ្សេងៗដែលកំពុងស្ថិតក្នុងស្ថានភាពដូចអ្នក។ ប៉ុន្តែត្រូវចាំថាមនុស្ស ជាច្រើនត្រូវបានគេជួញដូរដោយមនុស្សដែលគេស្គាល់។ | |
| ដើរជុំវិញផ្ទះអ្នកជិតខាងរបស់អ្នក៖ សិក្សាពីទីតាំងស្ថានីយ៍ប៉ូលីស កន្លែងចំណតរថយន្តក្រុង។ | |
| សួរគេរកមណ្ឌលសហគមន៍ ឬអង្គការ NGO ណាដែលមានផ្តល់សេវាជូនជនចំណាកស្រុក ឬកន្លែងដែលជាទីជួបជុំរបស់ជនចំណាកស្រុក។ ទៅមើលឲ្យដល់កន្លែងទាំងនេះផ្ទាល់។ | |
| ប្រសិនបើអ្នកសម្រេចចិត្តចង់ផ្ញើប្រាក់មកផ្ទះ សួរមិត្តភក្តិរបស់អ្នកពីមធ្យោបាយដែលអាចទុកចិត្តបានដើម្បីផ្ញើប្រាក់។ មិនត្រូវផ្ញើប្រាក់ទៅផ្ទះតាមស្រោមសំបុត្រ នោះទេពីព្រោះវាអាចនឹងត្រូវគេលួចយក។ | |

# ២៤ IS ២៤ខ ÷ រូបថ្លុកអំពីដំណាក់កាលនៃការធ្វើចំណាកស្រុក"

នៅក្នុងដំណាក់កាលនីមួយៗ នៃសំណួរសរសេរថ្លុកខាងក្រោមហើយតួអង្គស មានពពុះគំនិត ដោយ មិនមានពាក្យអ្វីទេ ដែលមានទំហំធំល្មមអាចឲ្យអ្នកចូលរួមសរសេរយោបល់របស់គេ។

## ឧទាហរណ៍នៃពពុះគំនិត:



**រូបទី ១ ៖ ស ធ្វើចំណាកស្រុក**
ឧទហរណ៍នៃពពុះគំនិត ៖ "ខ្ញុំបានទុកដាក់ឯកសាររបស់ខ្ញុំនៅក្នុងកន្លែងមានសុត្ថិភាព ហើយខ្ញុំនឹងមិននិយាយជាមួយមនុស្សមិនធ្លាប់ស្គាល់ឡើយ" ។



**រូបទី ២ ៖ ស ស្ថិតនៅឯស្ថានីយ៍រថយន្តក្រុង ។ មានស្ត្រីម្នាក់កំពុងព្យាយាមចូលជិតនាង ។ ស មិនអើពើពីស្ត្រីនោះ ហើយឡើងរថយន្តក្រុងក្នុងស្រុកមួយទៅជួបមិត្តភក្តិរបស់នាង។** ឧទហរណ៍នៃ ពពុះគំនិត ៖ "អត់ទេ អរគុណ។ ខ្ញុំមានគម្រោងត្រូវទៅជួបជាមួយមិត្តភក្តិរបស់ខ្ញុំរួចហើយ។"



**រូបទី ៣ ៖ ស បានមកដល់រោងចក្រមួយ ហើយពិនិត្យមើលមនុស្សដែលកំពុងធ្វើការនៅទីនោះ។** ឧទហរណ៍នៃ ពពុះគំនិត ៖"មុនពេលខ្ញុំចាប់ផ្តើមធ្វើការងារ ខ្ញុំបានទៅត្រួតពិនិត្យមើលកន្លែងដែលខ្ញុំនឹងទៅធ្វើការ។ ខ្ញុំនឹងធ្វើឲ្យបាជ្រកចំពោះការចុះកិច្ចសន្យាដើម្បីធានាថា ខ្ញុំទទួលបានប្រាក់ខែជារៀងរាល់ខែ ដូច្នេះមិនមាននរណាម្នាក់អាចកេងយកប្រយោជន៍ពីខ្ញុំបានទេ។"




**រូបទី ៤ ៖ ស បានដើរជុំវិញផ្ទះអ្នកជិតខាងក្បែរនោះ និងកំណត់ទីតាំងប៉ុស្តិ៍ប៉ូលីស។** ឧទហរណ៍នៃពពុះគំនិត ៖ "ខ្ញុំបានកំណត់ទីតាំងកន្លែងសំខាន់ៗអស់ហើយនៅក្បែររោងចក្រនោះ ហើយខ្ញុំបានដឹងពីវិធីទាក់ទងគេក្នុងករណីមានគ្រោះអាសន្ន។"




**រូបទី ៥ ៖ ស ស្ថិតនៅមណ្ឌលសហគមន៍សម្រាប់ជនចំណាកស្រុក កំពុងបង្កើតមិត្ត ភក្តិមួយចំនួន។** ឧទហរណ៍នៃ ពពុះគិត ៖ "ខ្ញុំនឹងសិក្សាថា តើជនចំណាកស្រុកផ្សេងទៀតមកពីណា និងជជែកជាមួយពួកគេ។"



**រូបទី ៦ ៖ ស បានទូរស័ព្ទមកផ្ទះដើម្បីប្រាប់ឪពុកម្តាយនាងអំពីកន្លែងដែលនាងកំពុងស្ថិតនៅ។** ឧទហរណ៍នៃ ពពុះគំនិត ៖ "ខ្ញុំនឹងធ្វើឲ្យប្រាដកថា គ្រួសាររបស់ខ្ញុំដឹងអំពីកន្លែងដែលខ្ញុំស្ថិតនៅដោយទូរស័ព្ទទៅពួកគាត់ជាទៀតទាត់។"



១. តើ ស បានធ្វើអ្វីខ្លះដើម្បីរក្សាសុវត្ថិភាពនៅលើរថយន្តក្រុង ?




២.តើ ស បានធ្វើអ្វីខ្លះដើម្បីរក្សាសុវត្ថិភាពនៅចំណតរថយន្តក្រុង?



៣.តើ ស បានធ្វើអ្វីខ្លះដើម្បីរក្សាសុវត្ថិភាពនៅកន្លែងធ្វើការថ្មីរបស់នាង ?




៤.តើ ស បានធ្វើអ្វីខ្លះដើម្បីរក្សាសុវត្ថិភាពនៅកន្លែងអ្នកជិតខាងរបស់នាង?




៥.តើ ស បង្កើតមិត្តភក្តិយ៉ាងដូចម្តេច?



៦.តើ ស ការពារខ្លួននាងយ៉ាងដូចម្តេច?

ប្រសិនបើអ្នកមានទូរស័ព្ទផ្ទាល់ខ្លួន អ្នកគួរយកវាទៅជាមួយ ពេលអ្នកធ្វើចំណាកស្រុក បន្តែ ស៊ីមកាតរបស់អ្នក នឹងមិនដំណើរការទេនៅប្រទេសផ្សេងនោះ។ អ្នកទិញស៊ីមកាត ថ្មីដែល មានបញ្ចូល ទឹកប្រាក់រួចជាស្រេចមុនសម្រាប់ទូរស័ព្ទរបស់អ្នកនៅពេល ដែលបានទៅដល់ ប្រទេសថ្មីនោះ។ ប្រសិនបើអ្នកមិនមានទូរស័ព្ទទេនៅ ប្រទេសគោលដៅ ជាច្រើនដូចជា ប្រទេសថៃ ឬប្រទេសម៉ាឡេស៊ីជាដើម មានកន្លែងប្រើអ៊ិនធឺណិតបង់ថ្លៃជាកន្លែងដែលអ្នកអាច ចំណាយប្រាក់ដើម្បីទូរស័ព្ទមកផ្ទះបាន។

**ដើម្បីហៅទូរស័ព្ទមកកាន់ប្រទេសកំណើតរបស់អ្នក ចូលធ្វើដូចខាក្រោម ៖**

**ចុច ៖** 001
**បន្ទាប់មក ៖** លេខកូដប្រទេសរបស់អ្នក
**បន្ទាប់ទៀត ៖** លេខទូរស័ព្ទនៅប្រទេសរបស់អ្នក ដោយកុំចុចលេខ 0 ដំបូង

**001 + លេខកូដប្រទេស + (មិនមានលេខសូន) + លេខទូរស័ព្ទ។**

ខាងក្រោមនេះគឺជាលេខកូដមួយចំនួនសម្រាប់ប្រទេសផ្សេងៗ ៖

| | | | |
|---|---|---|---|
| **កម្ពុជា ៖** | 855 | **ចិន ៖** | 86 |
| **ប្រទេសឡាវ ៖** | 856 | **វៀតណាម ៖** | 84 |
| **ប្រទេសថៃ ៖** | 66 | **មីយ៉ាន់ម៉ា ៖** | 95 |

(បុគ្គលិកប្រចាំប្រទេសរបស់អង្គការទស្សនពិភពលោក សូមរក្សាទុកលេខកូដ ប្រចាំប្រទេសទាំងអស់ ប៉ុន្តែគួសចំណាំតែលេខណាដែលពាក់ព័ន្ធនឹងប្រទេស របស់អ្នកបានហើយ។)

ឧទាហរណ៍ **ប្រសិនបើលេខទូរស័ព្ទរបស់អ្នកនៅក្នុងប្រទេសកម្ពុជា** គឺ 012 820 544 នោះពេលអ្នកហៅទូរស័ព្ទពីប្រទេសថៃមកគឺ

**អ្នកត្រូវចុច** 001 855 12 820 544

ឧទាហរណ៍ **ប្រសិនបើលេខទូរស័ព្ទរបស់អ្នកនៅក្នុងប្រទេសវៀតណាម** គឺ 018 442211 នោះពេលអ្នកហៅទូរស័ព្ទពីប្រទេសថៃមកគឺ

**អ្នកត្រូវចុច** 001 84 18 442 211

# ២៥ មេរៀនទី២៥ ៖ អ្វីដែលត្រូវធ្វើនៅពេលអ្នកត្រូវបានគេជួញដូរ

**វត្ថុបំណង**

អ្នកចូលរួមនឹងរៀនពី សេវាគាំទ្រនានាដែលជួយដល់ជនចំណាកស្រុក នឹងពិចារណាអំពីជម្រើសនានា របស់ជនចំណាកស្រុកដែលត្រូវបានគេជួញដូរ។

**ពេលវេលា**

៧៥ នាទី

**សម្ភារៈ**

- ថតចម្លងឯកសារ "IS ២៥ក៖ ស្ថានភាពលំបាក" (អ្នកចូលរួមនឹងប្រើឯកសារនេះនៅក្នុងក្រុមដែលមានគ្នាពី ៤ ឬ៥ នាក់)
- ឯកសារយោង "IS ២៥ខ ៖ តើត្រូវធ្វើអ្វីខ្លះប្រសិនបើអ្នកត្រូវបានគេជួញដូរ" និង"IS ២៥គ ៖ របៀបហៅទូរស័ព្ទពេលមានគ្រាអាសន្ន"
- កូនសៀវភៅនាវិកវៃឆ្លាត

**សេចក្តីផ្តើម**

**ការស្វាគមន៍**

ស្វាគមន៍អ្នកចូលរួមដោយហៅឈ្មោះ។

ហុចតៗគ្នានូវបញ្ជីចុះហត្ថលេខាវត្តមាន។

**សកម្មភាពមុនចាប់ផ្តើម**

ឲ្យអ្នកសម្របសម្រួលជាយុវជនដឹកនាំល្បែងថាមពលនៅក្នុងតារាង។

**ការរំឭកមេរៀន**

តើមាន នរណាបានទទួលការណែនាំពីឪពុកម្តាយ ពីរបៀបស្នាក់នៅដោយសុវត្ថិភាពពេលធ្វើចំណាកស្រុកដែរឬទេ? តើមានវិធីអ្វីខ្លះ?

តើមាននរណាដឹងទេថា មនុស្សដែលគេស្គាល់នៅតែមានទំនាក់ទំនងមកកាន់គ្រួសាររបស់គេដដែល បន្ទាប់ពីគេបានធ្វើចំណាកស្រុកដែរឬទេ?

## ការគ្រប់គ្រងរបស់អ្នកជួញដូរ

ពន្យល់ថា មេរៀននេះ និយាយអំពីអ្វីដែលត្រូវធ្វើប្រសិនបើពួកគេត្រូវបានជួញដូរ។ នេះគឺជាប្រធានបទដែលពិបាកពិភាក្សាពីព្រោះមិនមានចម្លើយងាយស្រួលនោះទេ។ ពន្យល់ថា អ្នកជួញដូរព្យាយាមអស់ពីលទ្ធភាពដើម្បីធ្វើឲ្យប្រាកដថា មនុស្សដែលធ្វើការឲ្យគេមិនអាចគេចខ្លួនរួច ឬទាក់ទងទៅកាន់អ្នកដទៃឲ្យជួយបាន។ ឲ្យក្រុមអ្នកចូលរួមគិតអំពីមធ្យោបាយដែលអ្នកជួញដូរមនុស្សគ្រប់គ្រងលើជនរងគ្រោះរបស់គេ។ មធ្យោបាយទាំងនេះរួមមាន ៖

- គំរាមកំហែងជនរងគ្រោះ
- អំពើហិង្សាលើរាងកាយ
- គំរាមកំហែងគ្រួសាររបស់ជនរងគ្រោះ
- ដាក់ជនរងគ្រោះឲ្យនៅតែឯង
- សន្យាថា នឹងផ្តល់ប្រាក់ឲ្យជនរងគ្រោះប្រសិនបើគេបានធ្វើការងាររយៈពេលយូរអង្វែង
- ផ្តល់គ្រឿងញៀនដល់ជនរងគ្រោះ

- គំរាមកំហែងថា និងប្រគល់ជនរងគ្រោះទៅឲ្យប៉ូលីសពីការរំលោភបំពានលើទិដ្ឋការ
- ចាក់សោរឃុំទុកជនរងគ្រោះនៅក្នុងកន្លែងធ្វើការ។

## ស្ថានភាពលំបាក

ប្រាប់អ្នកចូលរួមថា វាមានការលំបាកខ្លាំងណាស់ និងមានគ្រោះថ្នាក់ណាស់ក្នុងការរត់គេច ចេញពី អ្នកជួញដូរមនុស្ស។ បែងចែកអ្នកចូលរួមជាក្រុមដែលមានគ្នាពី ៤ ឬ៥នាក់ ហើយចែកឲ្យក្រុម នីមួយៗនូវ "IS ២៥ក៖ ស្ថានភាពលំបាក"។ ឲ្យក្រុមនីមួយៗជ្រើសរើសយក ស្ថានភាពទល់ច្រក មួយ និងពិចារណាអំពីអ្វីដែលគេគិតថា ជនរងគ្រោះនៃការជួញដូរគួរធ្វើក្នុង ករណីបែបនេះ។

## សេវាគាំទ្រនានា

ឲ្យអ្នកចូលរួមមើលកូនសៀវភៅនារីកវៃឆ្លាត និងមើលត្រង់ចំណុច "ការហៅទូរស័ព្ទពេលគ្រាអាសន្ន"។ ពន្យល់ថា ដោយសារតែជនចំណាកស្រុកតែងតែរកការងារធ្វើនៅប្រទេសផ្សេងនោះ តារាងនេះមានលេខទូរស័ព្ទពេលគ្រាមានអាសន្នសម្រាប់ប្រទេសជាច្រើន។

ពន្យល់ថា គួរទន្ទិញឲ្យចាំមាត់នូវលេខសម្រាប់គ្រាអាសន្នរបស់ប្រទេសកំណើតរបស់ខ្លួន និង លេខទូរស័ព្ទក្រុមគ្រួសារ ឬមិត្តភ័ក្ររបស់គេ។ មធ្យោបាយនេះមានន័យថា ប្រសិនបើគេបាត់លេខ គេនៅតែអាចហៅទូរស័ព្ទទៅកាន់លេខគ្រាអាសន្នបានដដែល។

បន្ទាប់មកទៀត ជួយអ្នកចូលរួមឲ្យទន្ទិញចាំមាត់នូវលេខទូរសព្ទ័គ្រាអាសន្នក្នុងប្រទេស។ អ្នកសម្របសម្រួល គួរសូត្រលេខជាចង្វាក់តន្ត្រី ឬដូចជាចម្រៀងមួយបទ ហើយបន្ទាប់មក ឲ្យអ្នកចូលរួមសូត្រ និងច្រៀងរាប់លេខត្រឡប់ថយក្រោយវិញក្នុងទម្រង់ដូចគ្នា។ ការសូត្រនេះអាចធ្វើឲ្យទៅជាចម្រៀងមួយបទ។ ឧទាហរណ៍ថា អ្នកសម្របសម្រួល: "១-១-៩-១ អ្នកហៅទៅកាន់ប៉ូលីសឲ្យមក។"

អ្នកចូលរួម: "១-១-៩-១ អ្នកហៅទៅកាន់ប៉ូលីសឲ្យមក។"

ធ្វើបែបនេះសារចុះឡើងរហូតទាល់តែអ្នកចូលរួមស្គាល់លេខនេះ។

## តើអ្នកត្រូវធ្វើអ្វីខ្លះប្រសិនបើអ្នកត្រូវបានគេជួញដូរ

សួរថា "តើអ្នកត្រូវធ្វើអ្វីខ្លះប្រសិនបើអ្នកត្រូវបានគេជួញដូរ?"

ឲ្យអ្នកចូលរួមបើកទៅចំណុច "តើអ្នកត្រូវធ្វើអ្វីខ្លះប្រសិនបើអ្នកត្រូវបានគេជួញដូរ?" នៅក្នុងកូនសៀវភៅនារីកវៃឆ្លាត(ព្រមទាំង "IS ២៥ខ៖ "តើអ្នកត្រូវធ្វើអ្វីខ្លះប្រសិនបើអ្នកត្រូវបានគេជួញដូរ ?"នៅខាងក្រោមផងដែរ។) ស្នើសុំម្នាក់ឲ្យឡើងអានឲ្យឮៗ។

ពន្យល់ថា ទំព័រនេះផ្តល់នូវដំបូន្មាន ប៉ុន្តែវិធានការទាំងនេះប្រហែលជាមិនគ្រប់គ្រាន់ដើម្បីជួយគេបានទេ ប្រសិនបើគេត្រូវបានជួញដូរនោះ។ អ្នកជួញដូរគឺជាឧក្រិដ្ឋជនប្រកបដោយគ្រោះថ្នាក់។ វាជាការល្អដែលត្រូវយកចិត្តទុកដាក់ ដូច្នេះគេនឹងមិនជួញដូនៅកន្លែងទីមួយទេ។

សួរថា តើមាននរណាធ្លាប់ជួបមនុស្សដែលរត់គេចខ្លួនពីការជួញដូរ ឬការកេងប្រវ័ញ្ចដែរ ឬទេ។ ប្រសិនបើមាន តើគេរត់គេចបានយ៉ាងដូចម្តេច?

## ការសម្តែងរឿង

ឲ្យអ្នកចូលរួមបែងចែកជាក្រុមមានគ្នាពី ៤ ឬ ៥នាក់ ។ ឲ្យក្រុមនីមួយៗជ្រើសរើសស្ថានភាពផ្សេងៗគ្នាពី "TS ២៥ក៖ ស្ថានភាពពិបាក" និងត្រូវរៀបចំត្រៀមសម្តែងរឿងអំពីស្ថានភាព។ ប្រាប់ទៅអ្នកចូលរួមថា គេមានពេល ប្រាំនាទីដើម្បីរៀបចំការសម្តែងរឿងនេះ។ ពន្ធាប់មកអនុវត្តការសម្តែងម្តងម្នាក់។

### សង្ខេបមេរៀន

- សិក្សាអំពីលេខទូរស័ព្ទគ្រាអាសន្នសម្រាប់ប្រទេសរបស់អ្នក និងប្រទេសគោលដៅ របស់អ្នក។
- ប្រសិនបើត្រូវបានគេជួញដូរនោះ ៖
  - ត្រូវកំណត់ទីតាំងរបស់អ្នកដោយសំឡឹងមើលឈ្មោះទីកន្លែង លេខផ្លូវធំ ឈ្មោះទីក្រុង អគារគេរកត់សម្គាល់ជាងគេ។ ការធ្វើបែបនេះមានន័យថា ប្រសិនបើអ្នកអាចទៅរកទូរស័ព្ទបាននោះអ្នកអាចប្រាប់គេឲ្យដឹងពីវិធីអាចរកអ្នកឃើញ។
  - ព្យាយាមសិក្សាពីឈ្មោះរបស់រោងចក្រ ភោជនីយដ្ឋាន ឬផ្ទះបន ដែលអ្នកកំពុងស្ថិតនៅ។
  - ត្រូវរៀបចំផែនការសិន មុនពេលអ្នកធ្វើសកម្មភាព
  - មិនត្រូវនៅធ្វើការទេ ប្រសិនបើថៅកែនិយាយថា គេនឹងមិនបើកប្រាក់ខែឲ្យអ្នកទេទាល់តែអ្នកបានធ្វើការរយៈពេលពេញមួយឆ្នាំសិន។
  - ហៅទូរស័ព្ទទៅកាន់លេខសម្រាប់គ្រាអាសន្ននៅក្នុងកូនសៀវភៅនាវិកវៃឆ្លាតរបស់អ្នក។
- ការពិតគឺ វាជាការលំបាកណាស់ក្នុងការរត់គេចចេញពីអ្នកជួញដូរមនុស្សនោះ។ ការសំខាន់បំផុត គឺត្រូវមានការប្រុងប្រយ័ត្នបំផុត ក្នុងការព្យាយាម រត់គេចចេញពីការជួញដូរនៅ កន្លែងទីមួយ។

## ការបិទបញ្ចប់

ប្រាប់ឲ្យអ្នកចូលរួមសរសេរ ឬសួរសំណួរ ផ្តល់ជាព័ត៌មានត្រឡប់ និងប្រគល់ឲ្យទៅអ្នកសម្របសម្រួលដោយមិនបាច់បញ្ចេញឈ្មោះ។

អរគុណដល់អ្នកចូលរួមទាំងអស់គ្នាដែលបានមកចូលរួម។ បញ្ជាក់ឡើងវិញ អំពីការប្រជុំក្លិបពេលក្រោយ។ ប្រាប់ពួកគេថា ពួកគេទទួលបានផ្កាយមួយទៀតសម្រាប់ការចូលរួមក្នុងមេរៀននេះ។

ឲ្យអ្នកចូលរួម សិក្សាពីលេខទូរស័ព្ទសម្រាប់គ្រាអាសន្ននៅក្នុងប្រទេសរបស់ខ្លួន និងនៅក្នុងប្រទេស គោលដៅរបស់គេ។



១. ស បានធ្វើការងារនៅលើទូកនេសាទមួយ។ នៅពេលដែលទូកចេញពីកំពង់ ស នដឹងច្បាស់ថា គេបានមានកំហុសយ៉ាងធំមួយ។ មេការលើទូកឲ្យពួកគេធ្វើការ ២០ ម៉ោងក្នុងមួយថ្ងៃ ហើយវាយដំគេនៅពេលមេការនោះខឹង។ នៅពេលដែលមិត្តរួមទូកមួយរបស់ ស ធ្លាក់ខ្លួនឈឺ មេការលើទូកបានចាប់បោះគេចេញពីទូកឲ្យលង់ទឹក។ ទូកនោះនៅក្នុងសមុទ្ររយៈពេល២ ខែ ហើយ ស មិនបានទទួលប្រាក់ខែអ្វីទាំងអស់។ នៅយប់មួយ គេបានរត់គេច ហើយបានហែលមកកាន់ច្រាំងវិញ។ គេមិនបានទទួលប្រាក់សូ ម្បីមួយសេនពីការងារដែលគេបានធ្វើនោះ ។ តើ ស គួរធ្វើបែបណា?



២. ម មានអាយុ ៩ ឆ្នាំ។ គេបានរលាកភ្លើងយ៉ាងដំណំកាលពីក្មេង ហើយមុខរបស់គេមានសំឡាកពេញទាំងអស់។ គ្រួសាររបស់គេបានឲ្យគេទៅសុំទាននៅក្នុងទីក្រុងទេសចរណ៍មួយកន្លែង។ គេបានគ្រប់គ្រងដោយបុរសម្នាក់ដែលបានយកគេទៅឲ្យសុំទានតាមដងផ្លូវនៅពេលព្រឹក ហើយទៅយកមកវិញនៅពេលយប់? គេទារយកលុយទាំងអស់ដែល ម សុំបាន។ បុរសនោះវាយដំគេ ហើយមិនដែលឲ្យលុយគេឡើយ។ តើ ម គួរធ្វើដូចម្តេច?



៣. ល ធ្វើការនៅក្នុងរោងចក្រមួយនៅក្នុងទីក្រុង។ នាងបានបង់ប្រាក់កក់ទៅឲ្យម្ចាស់រោងចក្រនោះដើម្បីបានការងារធ្វើ។ នាងបានធ្វើការ និងរស់នៅរោងចក្រនោះរយៈពេល បីខែ ប៉ុន្តែម្ចាស់រោងចក្រមិនទាន់បើកលុយឲ្យនាងទេ។ ម្ចាស់រោងចក្រនោះ កត់សម្គាល់នាង ហើយតែងតែមកប៉ះនាង និងប្រាប់នាងថា នាងស្អាត។ នាងមិនចូល ចិត្តឲ្យគេប៉ះបែបនេះទេ ហើយនាងព្យាយាមគេចេញពីបុរសនោះ។ តើ ល គួរធ្វើបែបណា?

- ប្រសិនបើអ្នក ត្រូវបានផ្លាស់ទីពីកន្លែងមួយទៅកន្លែងមួយទៀតដោយអ្នកជួញដូរនោះ អ្នកត្រូវបើកភ្នែកជានិច្ច ដើម្បីមើលស្លាក ឬសញ្ញាសម្គាល់ផ្សេងៗ។ ព្យាយាមគិតឲ្យចេញថាអ្នក កំពុងស្ថិតក្នុងកន្លែងណា។ រកមើលស្ថានីយ៍រថភ្លើងលេខ ផ្លូវជាតិ ឈ្មោះទីក្រុង ឬអគារគួរកត់សម្គាល់។ ចងចាំព័ត៌មានលម្អិត។ ការធ្វើបែបនេះមានន័យថា ប្រសិន បើ អ្នកអាចរកមធ្យោបាយហៅទូរស័ព្ទបានអ្នកអាចប្រាប់គេបានថា អ្នកកំពុងស្ថិតនៅកន្លែងណា។
- ប្រសិនបើ អ្នកកំពុងត្រូវគេបង្ខំឲ្យធ្វើផ្ទុយពីឆន្ទៈរបស់អ្នកនៅក្នុងកន្លែងធ្វើការ ដូចជានៅក្នុងផ្ទះបនមួយ ឬរោងចក្រមួយ ត្រូវព្យាយាមសិក្សាពីឈ្មោះទីកន្លែងដែលអ្នកកំពុងស្ថិតនៅហើយ ប្រសិនបើមានសុវត្ថិភាព ចូរនិយាយជាមួយមនុស្សនៅជុំវិញខ្លួនអ្នកដើម្បីស្វែងយល់ថាតើគេអាចអាចស្គាល់កន្លែងដែលអ្នកកំពុងស្ថិតនៅដែរ ឬទេ ។
- ត្រូវចងចាំមុខរបស់អ្នកជួញដូរ។
- ប្រសិនបើអ្នកគិតថា អ្នកត្រូវគេជួញដូរនោះ ត្រូវរៀបចំផែនការជាមុនសិន មុនធ្វើសកម្មភាព។ មិនត្រូវឲ្យអ្នកជួញដូរដឹងថា កំពុងថាអ្នកដឹងថាអ្នកកំពុងត្រូវបានគេជួញដូរឡើយ ដោយធ្វើធម្មតា ស្របពេលដែលអ្នកកំពុងរកផ្លូវរត់គេច។
- ប្រសិនបើអ្នកត្រូវគេជួញដូរដើម្បីលក់ផ្លូវភេទ អ្នកព្យាយាមបញ្ចុះបញ្ចូលឲ្យបុរស ប្រើប្រាស់ស្រោមអានាម័យ។
- ហៅទូរស័ព្ទទៅលេខគ្រាអាសន្នពីក្នុងកូនសៀវភៅនាវិកវៃឆ្លាតរបស់អ្នក។
- ប្រសិនបើអ្នក ត្រូវគេជួញដូរ ហើយមិនទទួលបានប្រាក់ខែនោះ ហើយថៅកែប្រាប់អ្នកប្រសិន បើអ្នកធ្វើការមួយឆ្នាំ ឬពីរឆ្នាំទៀត អ្នកនឹងទទួលបានប្រាក់ច្រើននោះ មិនត្រូវជឿថៅកែនោះទេ។ អ្នកជួញដូរតែងតែព្យាយាមបោកបញ្ឆោតជនចំណាកស្រុកតាមមធ្យោបាយបែបនេះហើយ ជនចំណាកស្រុកមិនដែលទទួលបានប្រាក់កាសអ្វីឡើយ។

## ប្រទេសកម្ពុជា

| | |
|---|---|
| ភ្នំពេញ ៖ | 017 276 222 |
| បាត់ដំបង ៖ | 017 256 222 |
| បន្ទាយមានជ័យ ៖ | 017 260 222 |
| សៀមរាប ៖ | 017 258 222 |
| កំពង់ធំ ៖ | 017 254 222 |
| កំពង់ឆ្នាំង | 017 326 222 |

## ប្រទេសវៀតណាម

លេខទូរស័ព្ទខាងក្រោមនេះ អាចប្រើប្រាស់បានដោយជនចំណាកស្រុកអាច ប្រើប្រាស់លេខទូរស័ព្ទខាងក្រោម ក្នុងករណី ជំនួយបន្ទាន់ ៖

1 800 1567 ៖ លេខទូរស័ព្ទ ជំនួយបន្ទាន់ករណីប្រឆាំងការជួញដូរ

(844) 3936 6633 ៖ មណ្ឌលធនធានទេសន្តរប្រវេសន៍ (MRC)

0694 4037 ៖ មន្ទីរស៊ើបអង្កេតឧក្រិដ្ឋកម្ម MPS

## ប្រទេសមីយ៉ាន់ម៉ា

លេខទូរស័ព្ទជំនួយបន្ទាន់ករណីប្រឆាំងការជួញដូរមាន ៖

| | |
|---|---|
| 95-67-412555 | 95-67-412666 |
| 95-949-555666 | 95-949-555777 |
| 95-949-555888 | 95-949-555999 |

អង្គការ UNIAP, UNICEF, IOM, Save the Youth, អង្គការទស្សនៈពិភពលោក ហើយ AFXB មានកម្មវិធីប្រឆាំងការជួញដូរ

## ប្រទេសចិន

| | |
|---|---|
| លេខជំនួយបន្ទាន់សម្រាប់មនុស្សយុវជន៖ | 12355 |
| លេខជំនួយបន្ទាន់សម្រាប់ស្ត្រី ៖ | 12338 |
| លេខជំនួយបន្ទាន់សម្រាប់សិទ្ធិពលកម្ម ៖ | 12333 |
| លេខជំនួយបន្ទាន់របស់សាលាក្រុង ៖ | 12345 |
| លេខជំនួយបន្ទាន់របស់ប៉ូលីស ៖ | 110 |

ក្រសួងកិច្ចការពលរដ្ឋ(MCA)មានសាខាគ្រប់ទិសទីក្នុងប្រទេសចិនដែលជន ចំណាកស្រុកអាចរកជំនួយបាន។

## ប្រទេសឡាវ

020 548 389 69

## ប្រទេសថៃ

ជនចំណាកស្រុកអាចហៅទៅលេខ 1300 ដើម្បីសុំជំនួយបាន។

នៅតាមខេត្តខ្លះលេខជំនួយបន្ទាន់មានអ្នកបក ប្រែដែល និយាយភាសាប្រទេសជិតខាង ទៀតផង៖

1191 ជាលេខទំនាក់ទំនងទៅកាន់ប៉ូលីសផ្នែកប្រឆាំងការជួញដូរ។

1417 ជាលេខសម្រាប់យុវជនហៅចូលដើម្បីសុំដំបូន្មាន។

# ២៦ មេរៀនទី២៦ ៖ ការឆ្លុះបញ្ចាំង ផ្លូវទៅរកការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព

## វត្ថុបំណង

អ្នកចូលរួម នឹងបង្ហាញពីអ្វីដែលគេបានរៀន តាមរយៈការគូររូបដែលបង្ហាញពីយុទ្ធសាស្ត្រនានាសម្រាប់ការធ្វើចំណាកស្រុប្រកបដោយសុវត្ថិភាព។

## ពេលវេលា

៧៥ នាទី

## សម្ភារៈ

- ក្រដាសវែងមួយសន្លឹងសម្រាប់អ្នកចូលរួមម្នាក់ៗ (ធ្វេឡើងដោយបិទក្រដាសធម្មតាបីសន្លឹកតគ្នាដើម្បីឲ្យគូសបន្ទាត់វែងបានមួយ)
- ប៊ិចពណ៌
- កូនសៀវភៅនាវិកវៃឆ្លាត

## សេចក្តីផ្តើម

### ការស្វាគមន៍

ស្វាគមន៍អ្នកចូលរួមដោយហៅឈ្មោះ។ ហុចតៗគ្នានូវបញ្ជីចុះហត្ថលេខាវត្តមាន។

### សកម្មភាពមុនចាប់ផ្តើម

ឲ្យអ្នកសម្របសម្រួលជាយុវជនដឹកនាំល្បែងថាមពលនៅក្នុងតារាង។

### ការរំឭកមេរៀន

តើលេខទូរស័ព្ទគ្រាអាសន្នសម្រាប់ប្រទេសរបស់អ្នកមានអ្វីខ្លះ? (ប្រសិនបើអ្នកចូលរួម ច្រឡំ អនុវត្តឡើងវិញ នូវដំណើរការកាលពីមេរៀនមុន ដែលក្រុមទាំងមូល បានផ្លាស់ប្តូរលេខជាមួយគ្នា)។

ចងចាំការទន្ទេញឲ្យរត់មាត់នូវលេខសម្រាប់គ្រាអាសន្នរបស់ប្រទេសគោលដៅ ប្រសិនបើអ្នកជ្រើសរើសធ្វើចំណាកស្រុក

### ការត្រិះរិះ

ពន្យល់ថា សៀវភៅឧបករណ៍នាវិកវៃឆ្លាតនេះមាននិយាយនូវព័ត៌មានជាច្រើន។ ខាងក្រោមនេះគឺជាសេចក្តីសង្ខេបអំពីប្រធានបទសំខាន់ដែលយើងបានសិក្សារួចហើយ។ អាន ការរៀបរាប់ខាងក្រោមនេះឲ្យឮៗទៅកាន់អ្នកចូលរួម។ ឈប់បន្ទាប់ពីចប់ប្រធានបទនីមួយៗ ហើយ សួរគេថា តើមេរៀននេះ និយាយអំពីអ្វី ហើយតើសកម្មភាពអ្វីខ្លះដែលគេបានធ្វើ។

- និយមន័យនៃការជួញដូរ។
- និយមន័យនៃការជួញដូរកុមារ។
- ភាពខុសគ្នារវាងការជួញដូរ និងការរត់ពន្ធមនុស្ស
- ការជួញដូរមនុស្សសម្រាប់គោលបំណងបម្រើសេវាផ្លូវភេទ រួមទាំង CSEC ផងដែរ។
- ការជួញដូរមនុស្សសម្រាប់ការកេងប្រវ័ញ្ច
- ការជួញដូរមនុស្សអាចកើតមានគ្រប់ទីកន្លែង
- ទំនាក់ទំនងរវាងការជួញដូរមនុស្ស និងការប្រើប្រាស់គ្រឿងញៀន
- ទំនាក់ទំនងរវាងការជួញដូរមនុស្ស និងយែនឌ័រ

- របៀបប្រើប្រាស់ជំនាញទំនាក់ទំនងបែបហ្មត់ចត់ និងជំនាញស្តាប់បានល្អដើម្បីការពារខ្លួនអ្នក។
- របៀបរៀបចំត្រៀមសម្រាប់ការធ្វើចំណាកស្រុកដោយសុវត្ថិភាព (គំរូនៃការសម្រេចចិត្ត និង តារាងត្រួតពិនិត្យ)។
- ការរក្សាខ្លួនឲ្យមានសុត្ថិភាពអំឡុងពេលកំពុងធ្វើដំណើរ។
- របៀបរក្សាខ្លួនឲ្យមានសុវត្ថិភាពបន្ទាប់ពីទៅដល់គោលដៅនៃការធ្វើចំណាកស្រុក។
- តើត្រូវធ្វើអ្វីខ្លះប្រសិនបើអ្នកត្រូវបានគេជួញដូរ។

## ការគូរផ្លូវទៅកាន់ការធ្វើចំណាកស្រុកដោយសុវត្ថិភាព

ឲ្យអ្នកចូលរួមយកចេញនូវ កូនសៀវភៅនារីកវៃឆ្លាតសម្រាប់ធ្វើជាឯកសារយោង។

ពន្យល់ថា ថ្ងៃនេះពួកគេនឹងត្រូវគូរបង្ហាញនូវរឿងមួយចំនួនដែលគេបានសិក្សារួច។ រូបគូរនេះ អាចមានទាំងរូបភាព និងអក្សរដែលពន្យល់ពីអ្វីដែលគេបានគូរ។

ការគូររូបនឹងចែកចេញជាបីផ្នែក

១. ការរៀបចំសម្រាប់ការធ្វើចំណាកស្រុក។

២. អំឡុងពេលកំពុងធ្វើដំណើរ ។

៣. នៅពេលអ្នកទៅដល់គោលដៅ ។

ឲ្យអ្នកចូលរួមគិតត្រឡប់វិញអំពីការរៀបរាប់ដែលបានអានរួច។ សួរអ្នកចូលរួមថា តើប្រធានបទអ្វីខ្លះ អ្វីខ្លះដែល គេគួរបញ្ចូលទៅក្នុងរូបភាពស្តីពី "រៀបចំសម្រាប់ការធ្វើចំណាកស្រុក" របស់គេ។

ចម្លើយអាចរួមមាន ៖

- ការដឹងអំពី អ្វីជាការជួញដូរ។
- ល្បិចទូទៅរបស់អ្នកជួញដូរ ។
- គំរូនៃការធ្វើសេចក្តីសម្រេចចិត្ត។
- តារាងត្រួតពិនិត្យ។
- ការជួញដូរអាចកើតមានគ្រប់ទីកន្លែង។
- ភាពខុសគ្នារវាងមិត្តភក្តិពិតប្រាកដ និងអ្នកជួញដូរ ។

សួរអ្នកចូលរួមថា តើប្រធានបទអ្វីខ្លះ ដែលគេគួរបញ្ចូលទៅក្នុងរូបភាពស្តីពី "អំឡុងពេលកំពុងធ្វើ ដំណើរ" របស់គេ។

ចម្លើយអាចរួមមាន ៖

- ល្បិចទូទៅរបស់អ្នកជួញដូរ ។
- ភាពខុសគ្នារវាងមិត្តភក្តិពិតប្រាកដ និងអ្នកជួញដូរ ។
- ការរក្សាខ្លួនឲ្យមានសុត្ថិភាពអំឡុងពេលកំពុងធ្វើដំណើរ។
- ជំនាញទំនាក់ទំនងបែបម៉ឺងម៉ាត់ និងជំនាញស្តាប់បានល្អ។

សួរអ្នកចូលរួមថា តើប្រធានបទអ្វីខ្លះដែលគេគួរបញ្ចូលទៅក្នុងរូបភាពស្តីពី "នៅពេលអ្នកទៅ ដល់គោលដៅ។" របស់គេ។

ចម្លើយអាចរួមមាន ៖

- របៀបរក្សាខ្លួនឲ្យមានសុវត្ថិភាពបន្ទាប់ពីទៅដល់គោលដៅ។
- ជំនាញទំនាក់ទំនងបែបម៉ឺងម៉ាត់ និងជំនាញស្តាប់បានល្អ។
- តើត្រូវធ្វើអ្វីខ្លះប្រសិនបើអ្នកត្រូវបានជួញដូរ។
- លេខទូរស័ព្ទទំនាក់ទំនងពេលមានអាសន្ន។
- ការជួញដូរមនុស្ស និងគ្រឿងញៀន។
- ភាពខុសគ្នារវាងមិត្តភក្តិពិតប្រាកដ និងអ្នកជួញដូរ។

ចែកក្រដាស និងប៊ិច ហើយពន្យល់ថា អ្នកចូលរួមនឹងមានពេល ៣០នាទីដើម្បីគូររូបនេះ ហើយបន្ទាប់មកគេនឹងត្រូវចែករំលែករូបគំនូររបស់គេ។

រំឭកដល់អ្នកចូលរួមថា វមិនសំខាន់ទេចំពោះការគូររូបស្អាតនោះ ។ អ្វីដែលសំខាន់នោះគឺគេត្រូវបង្ហាញនូវគំនិតរបស់គេ និងរៀបរាប់ពីសាច់រឿងមួយ។

ពេលដែលអ្នកចូលរួមកំពុងតែគូររូប ចូរដើរជុំវិញអ្នកចូលរួម ដោយលើកទឹកចិត្តដល់ពួកគេ។ រំឭកដល់គេនូវប្រធានបទដែលត្រូវដាក់បញ្ចូលពេលគេកំពុងគូរ។ ពន្យល់ថា គេអាចយក កូនសៀវភៅនារីកវៃឆ្លាតរបស់គេបានសម្រាប់ជាគំនិតពេលពួកគេកំពុងតែគូរ។

បន្ទាប់ពីរយៈពេលកន្លងទៅបាន ៣០ នាទី ឲ្យអ្នកចូលរួមចែករំលែកនូវរូបគំនូររបស់គេ។ ហើយប្រសិនបើនៅសល់ពេលទៀត សួរគេថា ៖

- តើអ្នកគិតថា SNYC ផ្លាស់ប្តូរទស្សនរបស់អ្នកដែរ ឬទេ ? បើមាន តើដោយរបៀបណា ?
- តើអ្នកគិតថា SNYC ផ្លាស់ប្តូរមធ្យោបាយដែលអ្នកនឹងធ្វើសកម្មភាពនៅពេលអនាគត់ដែរ ឬទេ ? បើមាន តើដោយរបៀបណា ?
- តើអ្វីដែលមានសារៈសំខាន់ជាងគេបំផុតដែលអ្នកបានរៀនចេះពី SNYC. ?

ពន្យល់អ្នកចូលរួមថា មិនមានសេចក្តីសង្ខេបទេក្នុងមេរៀននេះ ពីព្រោះនេះគឺជា មេរៀនបែបត្រិះរិះ។ ក៏មិនមានកំណត់ហេតុមេរៀនដែរ ដោយសារតែពេលវេលាមានកំណត់។

## ការបិទបញ្ចប់

ប្រាប់ឲ្យអ្នកចូលរួមសរសេរ ឬសួរសំណួរ និង/ឬ ផ្តល់ជាព័ត៌មានត្រឡប់ និងប្រគល់ឲ្យទៅអ្នកសម្របសម្រួលដោយមិនបាច់បញ្ចេញឈ្មោះ។

អរគុណដល់អ្នកចូលរួមទាំងអស់គ្នា ចំពោះការប្តេជ្ញាចិត្ត និងពេលវេលារបស់គេ។ ប្រាប់អ្នកចូលរួមថា សប្តាហ៍ក្រោយ យើងនឹងពិភាក្សាអំពីវិធានការមួយចំនួនដែលយើងអាចអនុវត្តបានដើម្បីចែករំលែកចំណេះដឹងដែលយើងបានរៀនចេះ។

# កំណត់ចំណាំ

សូមប្រើទំព័រនេះ ដើម្បីសរសេររាល់ការកំណត់ចំណាំផ្សេងៗ ដែលអ្នកចង់ចងចាំទុក នៅពេលត្រឡប់ទៅកាន់សហគមន៍របស់អ្នកវិញ។